# ព្រឹទ្ធសភា
SENATE MAGAZINE

## ទស្សនាវដ្តីខែមេសា







លេខ ៣០៦ ឆ្នាំទី២៦ ព.ស.២៥៦៩ គ.ស.២០២៦
Issue 306 Volume 26 B.E.2569 C.E.2026

# មាតិកា



១៣



២៧



២៩

## ក្របមុខ

*- សម្ដេចតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី អញ្ជើញសំណេះសំណាលជាមួយក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងថ្នាក់ដឹកនាំមន្ទីរ អង្គភាពនានាក្នុងខេត្តកំពង់ចាម។*
*- ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា អញ្ជើញបំពាក់ឯកសណ្ឋានជូនប្រជាការពារ នៅឃុំជើងព្រៃ ស្រុកបាធាយ ខេត្តកំពង់ចាម។*
*- ឯកឧត្តមបណ្ឌិត **ឆន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយក្រុមប្រឹក្សាសង្កាត់ ព្រះថៅអធិការវត្ត និងសិស្សានុសិស្ស នៅវត្តអម្ពផល (ហៅវត្តចុងកោះ) សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ៕*


**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម ឡាយ សំកុល

**អ្នកសម្របសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម ខេង សិទ្ធិគុណ
ឯកឧត្តម ជាម សុផលមករា
ឯកឧត្តម ជួន ណា
លោក ជួន សុខជី
លោក ទេព មករា
លោក កុក វ៉ៃ
លោក សុង សុខភារ័ត្ន

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ភារីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោកស្រី សុខ សុជាតា


## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-៣៤ )


- សារលិខិតថ្វាយព្រះពរ និងជូនពរសមាជិក សមាជិកាព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ គ.ស.២០២៦ ........................................១
- សម្ដេចតេជោ **ហ៊ុន សែន** ក្រើនរំលឹកដល់មន្ត្រីទាំងអស់ត្រូវចាំថា «មន្ត្រីមិនមែនជាចៅហ្វាយរបស់ប្រជាជននោះទេ គឺជាអ្នកបម្រើដ៏ស្មោះត្រង់របស់ប្រជាជន» ........................................ ៣
- សម្ដេចតេជោ **ហ៊ុន សែន** វាយតម្លៃខ្ពស់ចំពោះតួនាទីរបស់ CICA ក្នុងការលើកកម្ពស់សន្តិសុខ និងសន្តិភាព ទាំងនៅអាស៊ី និងលើពិភពលោក........................................៥
- សម្ដេចតេជោ លើកទឹកចិត្តវិនិយោគិនជប៉ុនបង្កើនការវិនិយោគលើសហគ្រាសខ្នាតតូចនិងមធ្យមនៅកម្ពុជា ........................................៦
- សម្ដេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសិង្ហបុរី ចូលជូនសារតាំង និងសម្ដែងការគួរសម ........................ ៧
- សម្ដេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យក្រុមការងារសមាគមជនជាតិខ្មែររស់នៅប្រទេសជប៉ុន ចូលជួបសម្ដែងការគួរសម....................៩
- សម្ដេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគីយ៉េប្រចាំកម្ពុជាចូលជួបសម្ដែងការគួរសម និងជម្រាបលា ...១០
- សម្ដេចតេជោ **ហ៊ុន សែន** ចង់ឃើញកម្ពុជានិងវៀតណាមសម្រេចទំហំពាណិជ្ជកម្មកើនដល់២០ពាន់លានដុល្លារ ........................ ១១
- សម្ដេចតេជោ **ហ៊ុន សែន** ទោះស្ថានភាពពិភពលោកប្រែប្រួលក្ដី តែទំនាក់ទំនងកម្ពុជា និងចិនមិនប្រែប្រួលនោះទេ ........................ ១៣
- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់និងសេចក្ដីស្នើច្បាប់ចំនួន២ ........................................១៥
- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាសម្រេចបើកសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់និងសេចក្ដីស្នើច្បាប់ចំនួន២ ....................១៦
- ព្រឹទ្ធសភាឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ស្ដីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានិងសេចក្ដីស្នើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា........................................ ១៧
- ព្រឹទ្ធសភាប្រារព្ធពិធីសូត្រមន្តចម្រើនសិរីមង្គល ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ........................................១៩
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងគណៈកម្មការទី១០ព្រឹទ្ធសភា និងវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា...២១
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីជួបសំណេះសំណាល ប្រគល់ឯកសណ្ឋាន និងសម្ភារៈជូនប្រជាការពារ នៅស្រុកបាធាយ ខេត្តកំពង់ចាម ....................២៣
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជួបពិភាក្សាការងារជាមួយគណៈប្រតិភូសភាឡាវ រូម៉ានី និងម៉ារុក ក្នុងអំឡុងមហាសន្និបាតលើកទី១៥២ នៃសហភាពអន្តរសភា (IPU) ................២៥
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជួបពិភាក្សាការងារជាមួយប្រធានរដ្ឋសភាជាតិតួកគីយ៉េ និងគណៈប្រតិភូជាន់ខ្ពស់នៃសភាជាតិហុងគ្រី ក្នុងអំឡុងមហាសន្និបាត IPU លើកទី១៥២ ... ២៧
- កម្ពុជាប្តេជ្ញាចិត្តខ្ពស់ក្នុងការលុបបំបាត់បទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីការពារសុវត្ថិភាពពលរដ្ឋ និងកិត្យានុភាពជាតិ........................................២៩
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........................................ ៣១


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ៣៥-៥៨ )


- គណៈកម្មការទី៨ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនសមាគមស្នាមញញឹមថ្មីនៃក្តីសង្ឃឹមរបស់កុមារ ........................................៣៥
- ឯកឧត្តម **ម៉ម ប៊ុននាង** អញ្ជើញនាំយកអំណោយមនុស្សធម៌ ក្នុងទំហំទឹកប្រាក់ប្រមាណជាងមួយលានប្រាំសែនដុល្លារអាមេរិក ប្រគល់ជូនរដ្ឋបាលខេត្តស្វាយរៀង.................. ៣៧
- ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកចង្ក្រានសន្សំសំចៃថាមពល ចែកជូនប្រជាពលរដ្ឋនៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង........................................៣៩
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា........................................៤១
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស........................................៤៥
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨........................................៤៦
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........................................៥៦
- ការទទួលពាក្យបណ្ដឹង........................................៥៨


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៥៩-៦៤ )


- ឯកឧត្តម **ឡាយ សំកុល** អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈនិងខែមីនា និងលើកទិសដៅការងារខែមេសា ឆ្នាំ២០២៦........................................៥៩
- សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ........................................៦១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា**

## សារលិខិតថ្វាយព្រះពរ និងជូនពរ
## សមាជិក សមាជិកាព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
## និង ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
## ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក
## ព.ស.២៥៧០ គ.ស.២០២៦

**សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អានដ៏ជ្រាលជ្រៅ!**

ក្នុងឱកាសអភិមង្គលដ៏មហាបវរនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ គ.ស.២០២៦ ដែលនឹងឈានចូលមកដល់នៅថ្ងៃអង្គារ ១២រោច ខែចេត្រ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស.២០២៦ វេលាម៉ោង ១០:៤៨នាទីព្រឹកនេះ ក្នុងនាមព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមទូលព្រះបង្គំខ្ញុំផ្ទាល់ ទូលព្រះបង្គំ ខ្ញុំសូមសម្តែងនូវអំណរសាទរយ៉ាងកក់ក្តៅ និងសព្ទសាធុការពរគ្រប់ប្រការថ្វាយ និងជូនចំពោះ**អង្គព្រឹទ្ធសភា** និង**ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា** ព្រមទាំងក្រុមគ្រួសារ។

ខ្ញុំសូមកោតសរសើរ និងសូមថ្លែងអំណរគុណចំពោះ **ព្រឹទ្ធសភាទាំងមូល** ដែលបានខិតខំបំពេញភារកិច្ចការងារតាមមុខងារ និងតួនាទីរៀងៗខ្លួន អស់ពីកម្លាំងកាយចិត្តមិនខ្លាចនឿយហត់ ក្នុងស្មារតីភ្ញាក់រលឹក និងទទួលខុសត្រូវខ្ពស់ ជួយធ្វើឱ្យព្រឹទ្ធសភាដំណើរការទៅដោយរលូន និងជោគជ័យ។ ក្រៅពីបំពេញមុខងារស្នូលទាំងបី ព្រឹទ្ធសភាក៏បានបំពេញបេសកកម្មការងារយ៉ាងសកម្មនៅតាមបណ្តាភូមិភាគនៅទូទាំងប្រទេស ដើម្បីស្វែងយល់ពីវឌ្ឍនភាព និងដោះស្រាយតម្រូវការ បញ្ហាប្រឈម និងក្តីកង្វល់នានារបស់ប្រជាជន។ ពិសេសជាងនេះទៅទៀត បន្ទាប់ពីមានបទឈប់បាញ់លើកទីពីរនៃសង្គ្រាមឈ្លានពានរបស់ទាហានថៃ ដែលចូលជាធរមាននៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ព្រឹទ្ធសភាទាំងមូល នៅតែបន្តចុះជួយបងប្អូនវីរកងទ័ពជួរមុខ ចុះជួបសួរសុខទុក្ខនិងជូនអំណោយជនភៀសសឹកទាំងអស់ ជាពិសេសបងប្អូនភៀសសឹកស្នាក់នៅទីជម្រកបណ្តោះអាសន្ន ដែលមិនទាន់បានត្រឡប់ទៅកាន់លំនៅឋានវិញនៅតាមតំបន់ព្រំដែនជាប្រចាំក្នុងស្មារតីសាមគ្គីភាពរឹងមាំ។

ព្រឹទ្ធសភា ក៏នៅតែបន្តបំពេញសកម្មភាពការទូតសភា ផ្សព្វផ្សាយការពិតអំពីការឈ្លានពានទន្ទ្រាន កាន់កាប់ទឹកដីកម្ពុជាដោយយោធាថៃមុននិងក្រោយបទឈប់បាញ់ និងស្វែងរកការគាំទ្រនៅគ្រប់ក្របខណ្ឌ ទាំងទ្វេភាគី និងពហុភាគី តាមរយៈការចូលរួមក្នុងវេទិកាអន្តរសភានានាក្នុងស្រុក តំបន់ និងលើពិភពលោក និងជួបជាមួយឥស្សរជនជាន់ខ្ពស់ជាថ្នាក់ដឹកនាំ ឬសមាជិកសភា រួមទាំងរដ្ឋាភិបាលនៃបណ្តាប្រទេសជាមិត្ត សំដៅលើកតម្កើងកិត្យានុភាពជាតិលើឆាកអន្តរជាតិ ក៏ដូចជាបង្ហាញពីតួនាទី

យ៉ាងសំខាន់របស់សភាកម្ពុជា ក្នុងការរួមចំណែកថែរក្សា ការពារសុខសន្តិភាព និងវិបុលភាពក្នុងតំបន់ រួមទាំងពិភពលោកផងដែរ។

ទោះបីជាមានបទឈប់បាញ់ពីរលើកក៏ដោយ ក៏សភាពការណ៍នៅតាមព្រំដែនកម្ពុជា-ថៃ នៅមានភាពផុយស្រួយនៅឡើយ។ **ព្រឹទ្ធសភាទាំងមូល** ក្រោមការដឹកនាំរបស់ទូលព្រះបង្គំ ខ្ញុំ ក៏នៅតែរួមគ្នាជាកម្លាំងមហាសាមគ្គីដ៏ស្អិតរមួតជាធ្លុងមួយ គាំទ្រដោយជឿជាក់យ៉ាងមុតមាំលើរាជរដ្ឋាភិបាលកម្ពុជា វីរកងទ័ព វីរនគរបាលការពារព្រំដែន ក្រោមការដឹកនាំរបស់**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ក្រោមបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី ទន្ទឹមនឹងការត្រៀមខ្លួនជានិច្ចក្នុងការប្រយុទ្ធការពារខ្លួន តតាំងទប់ទល់ដោយមិនរាថយនឹងសត្រូវឈ្លានពាន ក្នុងបុព្វហេតុការពារឱ្យបានដាច់ខាតនូវដែនអធិបតេយ្យ បូរណភាពទឹកដីកម្ពុជាយើង។

ជាថ្មីម្តងទៀត ទូលព្រះបង្គំ ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ជាពិសេសទេវតាឆ្នាំថ្មីព្រះនាម **រាក្សសាទេវី** សូមព្រះមេត្តាយាងបីបាច់ថែរក្សា ប្រោះព្រំនូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការថ្វាយ និងជូនពរ **សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម និងលោកជំទាវ** ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ទទួលបាននូវជោគជ័យថ្មីទៀត និងសូមសមប្រកបដោយពុទ្ធពរ និងពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវមនោសញ្ចេតនាគោរពរាប់អានដ៏ជ្រាលជ្រៅពីទូលព្រះបង្គំ ខ្ញុំ។

ថ្ងៃពុធ ៦រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមករា ឆ្នាំ២០២៦



**ហ៊ុន សែន**

# សម្តេចតេជោ ហ៊ុន សែន ក្រើនរំលឹកដល់មន្ត្រីទាំងអស់ត្រូវចាំថា «មន្ត្រីមិនមែនជាចៅហ្វាយរបស់ប្រជាជននោះទេ គឺជាអ្នកបម្រើដ៏ស្មោះត្រង់របស់ប្រជាជន»

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានក្រើនរំលឹកដល់មន្ត្រីទាំងអស់ត្រូវចាំថា «មន្ត្រីមិនមែនជាចៅហ្វាយរបស់ប្រជាជននោះទេ គឺជាអ្នកបម្រើដ៏ស្មោះត្រង់របស់ប្រជាជន» និងចៀសវាងភាពអសកម្ម ឬការគាបសង្កត់ណាមួយដល់ប្រជាពលរដ្ឋ។



*សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី*

ការក្រើនរំលឹកនេះ ធ្វើឡើងក្នុងឱកាស**សម្តេចតេជោ** អញ្ជើញជួបសំណេះសំណាលជាបន្តបន្ទាប់ជាមួយក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ថ្នាក់ដឹកនាំមន្ទីរ និងអង្គភាពនានាក្នុងខេត្តកំពង់ចាមចំនួន១.១៩៣នាក់ និងនៅខេត្តត្បូងឃ្មុំចំនួន៨៨៩នាក់ នៅព្រឹកថ្ងៃសៅរ៍ ទី២៥ និងព្រឹកថ្ងៃអាទិត្យ ទី២៦ ខែមេសា ឆ្នាំ២០២៦។

នៅគ្រប់ឱកាសជួបសំណេះសំណាលនាពេលនោះ **សម្តេចតេជោ** បានបង្ហាញនូវក្តីរីករាយ ដែលបានអញ្ជើញមកជួបជាមួយបងប្អូនក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងថ្នាក់ដឹកនាំមន្ទីរអង្គភាពនានាក្នុងខេត្តទាំងពីរសាជាថ្មី។ **សម្តេច**បានកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះមន្ត្រីរាជការទាំងអស់ដែលបានខិតខំបំពេញការងារបម្រើសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ជាពិសេសការរួមគ្នារក្សាឱ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងសង្គម និងទប់ស្កាត់បាននូវរាល់ទង្វើបង្កចលាចលនានា។

**សម្តេចតេជោ** បានណែនាំដល់មន្ត្រីរាជការទាំងអស់ជាពិសេសក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបន្តយកចិត្តទុកដាក់បំពេញតួនាទីភារកិច្ចបម្រើជាតិនិងប្រជាជនឱ្យបានល្អប្រសើរ ជាពិសេសបន្តយកចិត្តទុកដាក់ផ្តល់នូវសេវាចាំបាច់នានា ជូនប្រជាពលរដ្ឋឱ្យបានលឿន រហ័ស និងចៀសវាងបង្កនូវបញ្ហាដែលនាំឱ្យមានការថ្នាំងថ្នាក់ដល់ទឹកចិត្តរបស់ប្រជាពលរដ្ឋ។

**សម្តេចតេជោ** ក៏បានរំលឹកដល់មន្ត្រីទាំងអស់



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលនៅខេត្តកំពង់ចាម*



*សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ថ្នាក់ដឹកនាំមន្ទីរ និងអង្គភាពនានាក្នុងខេត្តត្បូងឃ្មុំ*

ត្រូវបន្តយកចិត្តទុកដាក់រក្សាឱ្យបានស្ថិរភាព សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ដោយបន្តអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព រួមមាន ការបង្ក្រាបនូវបទល្មើស ផ្សេងៗ ដូចជា ចោរឆក់ ចោរប្លន់ និងការជួញដូរគ្រឿងញៀន ជាពិសេសបង្ក្រាបឱ្យបាននូវអំពើឆបោកតាមអនឡាញ (Online Scams)។

ទន្ទឹមនឹងនេះ **សម្តេចតេជោ** ក៏បានជំរុញឱ្យអាជ្ញាធរ មូលដ្ឋានត្រូវចូលរួមទាំងអស់គ្នា គាំទ្រដល់ការប្រមូលចំណូល ទាំងផ្នែកពន្ធគយនិងពន្ធដារ ចូលរួមថែរក្សាធនធានធម្មជាតិ ដែលមាននៅមូលដ្ឋាន ទប់ស្កាត់ការបំផ្លិចបំផ្លាញ និងរួមគ្នា ថែរក្សាឱ្យបានគង់វង្ស ហើយអាជ្ញាធរត្រូវយកចិត្តទុកដាក់ ដោះស្រាយជម្លោះដីធ្លីជូនប្រជាពលរដ្ឋឱ្យបានរហ័សនិង មានប្រសិទ្ធភាព ជាពិសេសការដោះស្រាយវិវាទក្រៅប្រព័ន្ធ តុលាការ ដោយមិនត្រូវលម្អៀងខាងភាគីណានោះទេ។

សូមជម្រាបថា គោលបំណងនៃពិធីសំណេះសំណាល នេះ គឺជាការអនុវត្ត ក៏ដូចជាការពង្រឹងគណនេយ្យភាពរវាង ព្រឹទ្ធសភាជាមួយអង្គបោះឆ្នោត ដើម្បីឱ្យមានតម្លាភាពនិង ជំរុញឱ្យការងារមូលដ្ឋានកាន់តែមានប្រសិទ្ធភាព ព្រមទាំង ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធជាមួយអាជ្ញាធរ មូលដ្ឋាននិងក្រើនរំលឹកដល់មន្ត្រីនៅមូលដ្ឋានបង្កើនការ យកចិត្តទុកដាក់លើភារកិច្ចដែលជាដែនសមត្ថកិច្ចរបស់ខ្លួន ទន្ទឹមនឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបាន ល្អប្រសើរ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលនៅខេត្តត្បូងឃ្មុំ*

# សម្តេចតេជោ ហ៊ុន សែន វាយតម្លៃខ្ពស់ចំពោះតួនាទីរបស់ CICA ក្នុងការលើកកម្ពស់សន្តិសុខ និងសន្តិភាព ទាំងនៅអាស៊ី និងលើពិភពលោក

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានវាយតម្លៃខ្ពស់ចំពោះតួនាទីរបស់ CICA (Conference on Interaction and Confidence Building Measures in Asia) ដែលបានចូលរួមចំណែកក្នុងការលើកកម្ពស់សន្តិសុខ និងសន្តិភាព ទាំងនៅអាស៊ី និងនៅលើពិភពលោក។




*ឯកឧត្តម កៃរ៉ាត់ សារីបៃ និងសម្តេចតេជោ ហ៊ុន សែន*

ការវាយតម្លៃនេះធ្វើឡើងក្នុងឱកាស **សម្តេចតេជោ** អនុញ្ញាតឱ្យ ឯកឧត្តម **កៃរ៉ាត់ សារីបៃ** (Kairat Sarybay) អគ្គលេខាធិការនៃសន្និសីទស្តីពី អន្តរកម្ម និងវិធានការកសាងទំនុកចិត្តនៅអាស៊ី (CICA) ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃអង្គារ ទី៣១ ខែមីនា ឆ្នាំ២០២៦។

**សម្តេចតេជោ** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះ **ឯកឧត្តមអគ្គលេខាធិការ**និងសហការី ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា ហើយសង្ឃឹមថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តមទៅកាន់ខេត្តសៀមរាប នឹងធ្វើឱ្យឯកឧត្តមពេញចិត្តនឹងប្រាសាទបុរាណជាច្រើនរបស់កម្ពុជា និងភាពស្រស់ស្អាតនៅទីនោះ។

**សម្តេចតេជោ** បានគូសបញ្ជាក់ថា តាមរយៈវេទិកា CICA បានរួមចំណែកក្នុងការតភ្ជាប់គ្នារវាងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ី ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍និងតំបន់អាស៊ីកណ្តាល តួយ៉ាងដូចជានៅប្រទេសកៀហ្ស៊ីស៊ីស្ថាននិងអាស៊ែបៃហ្សង់ជាដើម ដែលជាផ្នែកមួយនៃសហប្រតិបត្តិការដ៏ល្អរវាងបណ្តាប្រទេសនៅតំបន់អាស៊ី។

នៅក្នុងជំនួបនោះ **ឯកឧត្តមអគ្គលេខាធិការ** បានសម្តែងនូវការអរគុណចំពោះ**សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យឯកឧត្តមនិងសហការី ចូលជួបសម្តែងការគួរសម និងបានពេញចិត្តចំពោះភាពស្រស់ស្អាតនៅកម្ពុជា ជាពិសេសក្នុងពេលដែលឯកឧត្តមបានអញ្ជើញទៅកាន់ខេត្តសៀមរាប នឹងបានឃើញនូវប្រាសាទបុរាណរបស់កម្ពុជារាប់ពាន់ឆ្នាំ ដែលពោរពេញទៅដោយអត្ថន័យនៃប្រវត្តិសាស្ត្រដ៏ស៊ីជម្រៅ។

ឯកឧត្តមបានកោតសរសើរចំពោះភាពជាអ្នកដឹកនាំរបស់**សម្តេចតេជោ**តាំងពីនៅជានាយករដ្ឋមន្ត្រី ជាពិសេសការកសាងសន្តិភាពនៅកម្ពុជា រួមទាំងលើឆាកអន្តរជាតិ តាមរយៈការចូលរួមជាមួយអង្គការអន្តរជាតិនានារួមមានទាំងអាស៊ាន ជាពិសេសការចូលរួមយ៉ាងសកម្មរបស់កម្ពុជានៅក្នុងសហប្រតិបត្តិការដ៏ល្អជាមួយ CICA ក្នុងគោលដៅលើកកម្ពស់សហប្រតិបត្តិការអន្តរជាតិ ថែរក្សាសន្តិសុខ និងសន្តិភាព នៅក្នុងពិភពលោក។

**ឯកឧត្តមអគ្គលេខាធិការ** បានលើកឡើងអំពីសហប្រតិបត្តិការបន្ថែមទៀតនៅក្នុងក្របខ័ណ្ឌកម្ពុជា និង CICA ទាំងក្នុងវិស័យទេសចរណ៍ វិស័យអប់រំ និងវិស័យពាណិជ្ជកម្ម ក្នុងការពង្រីកទំនាក់ទំនងទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគីនៃបរិបទកម្ពុជាជាមួយ CICA និងបណ្តាសមាជិករបស់ CICA ផងដែរ។



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារនិងសម្តែងការគួរសម*

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តមអគ្គលេខាធិការ**និងសហការី សូមបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ប្រកបដោយភាពជោគជ័យ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ លើកទឹកចិត្តវិនិយោគិនជប៉ុនបង្កើនការវិនិយោគ លើសហគ្រាសខ្នាតតូចនិងមធ្យមនៅកម្ពុជា



*សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកឧត្តម តាកាហ៉ាស៊ី ហ្វូមីអាគី ចូលជួបពិភាក្សាការងារនិងសម្តែងការគួរសម*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថា ក្នុងអំឡុងពេលដែល**សម្តេច**ធ្វើជានាយករដ្ឋមន្ត្រី **សម្តេចតេជោ** បានផ្តោតសំខាន់លើការវិនិយោគផ្នែកសហគ្រាសខ្នាតតូច និងមធ្យម ព្រមទាំងបានជំរុញឱ្យមានការវិនិយោគយ៉ាងផុលផុស ពីព្រោះ**សម្តេច**បានចាត់ទុកសហគ្រាសខ្នាតតូច និងមធ្យម គឺជាចលករនៃការជ្រោមជ្រែងដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា។ **សម្តេច**បានលើកឡើងយ៉ាងដូច្នេះ ក្នុងឱកាសដែល**សម្តេច**អនុញ្ញាតឱ្យឯកឧត្តម **តាកាហ៉ាស៊ី ហ្វូមីអាគី** (TAKAHASHI Fumiaki) ប្រធានសមាគមជប៉ុន-កម្ពុជា (Japan-Cambodia Association) ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦។

**សម្តេចតេជោ** បានសម្តែងនូវការស្វាគមន៍និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងការងាររបស់សមាគមជប៉ុន-កម្ពុជាដែលបានទាក់ទាញវិនិយោគិនជប៉ុនមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា។

នៅក្នុងជំនួបនោះ **ឯកឧត្តមប្រធានសមាគម** បានថ្លែងអំណរគុណចំពោះ**សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យឯកឧត្តមនិងសហការី បានចូលជួបសម្តែងការគួរសម។ ឯកឧត្តមបានកោតសរសើរចំពោះការរីកចម្រើនរបស់កម្ពុជា ដោយរៀងរាល់ពេលដែលឯកឧត្តមមកដល់ប្រទេសកម្ពុជា ឯកឧត្តមតែងតែឃើញភាពរីកចម្រើនថ្មីៗជាបន្តបន្ទាប់និងមានមោទនភាពដែលបានចូលរួមចំណែកក្នុងការទាក់ទាញវិនិយោគិនឱ្យមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា។

**ឯកឧត្តមប្រធានសមាគម** បានលើកឡើងពីសក្តានុពលរបស់កម្ពុជា នៅក្នុងការវិនិយោគផ្នែកសហគ្រាសខ្នាតតូច និងមធ្យម ដែលសមាគមបានចាប់អារម្មណ៍ ព្រមទាំងកំពុងជំរុញការវិនិយោគខ្នាតតូច និងមធ្យមនៅកម្ពុជាឱ្យបានកាន់តែច្រើន។ ឯកឧត្តមក៏បានកោតសរសើរចំពោះសក្តានុពលធនធានធម្មជាតិដ៏សម្បូរបែបរបស់កម្ពុជា។ ឯកឧត្តមក៏បានលើកឡើងថា ការបូកបញ្ចូលគ្នារវាងធនធានធម្មជាតិរបស់កម្ពុជានិងបច្ចេកវិទ្យារបស់ជប៉ុន អាចនាំឱ្យកម្ពុជាបង្កើតបាននូវផលិតផលជាច្រើនទៀត ដើម្បីនាំចេញទៅក្រៅប្រទេស។

**សម្តេចតេជោ** បានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាពរីកចម្រើនរបស់សមាគមដែលបានទាក់ទាញអ្នកវិនិយោគពីប្រទេសជប៉ុនមកបណ្តាក់ទុនវិនិយោគនៅកម្ពុជាកាន់តែច្រើន។ **សម្តេច**បានលើកឡើងថា សមាគមជប៉ុន-កម្ពុជា បានចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ហើយរដ្ឋាភិបាលជប៉ុនក៏បានខិតខំប្រឹងប្រែងជួយផ្តល់ជំនួយដល់កម្ពុជាបានយ៉ាងច្រើនផងដែរ។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរដល់ឯកឧត្តម **តាកាហ៉ាស៊ី ហ្វូមីអាគី** និងសហការី ឱ្យបំពេញទស្សនកិច្ចនៅកម្ពុជាប្រកបដោយជោគជ័យ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសិង្ហបុរី ចូលជូនសារតាំង និងសម្តែងការគួរសម



*ឯកឧត្តម Steven Pang Chee Wee ជូនសារតាំងសម្តេចតេជោ ហ៊ុន សែន*

នៅព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Steven Pang Chee Wee ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព នៃសាធារណរដ្ឋសិង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជូនសារតាំងនិងសម្តែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

ក្នុងព្រះបរមនាមរបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចតេជោ** បានអបអរសាទរចំពោះឯកឧត្តម Steven Pang Chee Wee ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ **សម្តេច** បានចាត់ទុកវត្តមានដ៏ឆាប់រហ័សរបស់ឯកឧត្តម Steven Pang Chee Wee មកកាន់តំណែងជាឯកអគ្គរដ្ឋទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់អំពីគុណតម្លៃនិងការផ្តល់តម្លៃរបស់សិង្ហបុរីចំពោះទំនាក់ទំនងជាមួយកម្ពុជា។

ក្នុងឱកាសនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានលើកឡើងថា ប្រទេសកម្ពុជានិងសិង្ហបុរីមានទំនាក់ទំនងយូរអង្វែងជាមួយគ្នា ហើយកាលពីឆ្នាំ២០២៥ កន្លងទៅ ប្រទេសទាំងពីរបានប្រារព្ធខួប៦០ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូតផ្លូវការជាមួយគ្នា ព្រមទាំងការផ្លាស់ប្តូរដំណើរទស្សនកិច្ចទៅវិញទៅមករវាងថ្នាក់ដឹកនាំកំពូលរវាងប្រទេសទាំងពីរ បានបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងដ៏រឹងមាំរវាងកម្ពុជានិងសិង្ហបុរី។

**ឯកឧត្តមឯកអគ្គរដ្ឋទូត**ជឿជាក់ថា នៅក្នុងអាណត្តិរបស់ឯកឧត្តម ឯកឧត្តមនឹងខិតខំប្រឹងប្រែងពូនជ្រំទំនាក់ទំនងរវាងកម្ពុជានិងសិង្ហបុរីឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ជាពិសេសការពង្រីកទំនាក់ទំនងទាំងការទូត នយោបាយ ពាណិជ្ជកម្ម សេដ្ឋកិច្ច និងការវិនិយោគ។ ឯកឧត្តមបានសង្កត់ធ្ងន់ថា នឹងខិតខំប្រឹងប្រែងក្នុងការកៀរគរវិនិយោគិនសិង្ហបុរី មកវិនិយោគនៅកម្ពុជាឱ្យកាន់តែច្រើនបន្ថែមទៀត និងពង្រីកទំនាក់ទំនងរវាងប្រជាជននិងប្រជាជននៃប្រទេសទាំងពីរ ឱ្យកាន់តែមានភាពស្អិតល្មួតនិងច្រើនឡើងថែមទៀត។

ជាការឆ្លើយតប **សម្តេចតេជោ** បានពេញចិត្តចំពោះការលើកឡើងរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ចំពោះការប្តេជ្ញាចិត្តក្នុងការពង្រីកទំនាក់ទំនងរវាងកម្ពុជានិងសិង្ហបុរីឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។ **សម្តេច**ឯកភាពចំពោះការលើកឡើងរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ទាក់ទងនឹងការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ ដែលបង្ហាញយ៉ាងច្បាស់អំពីចំណងមិត្តភាពដ៏រឹងមាំនៃប្រទេសទាំងពីរ។ **សម្តេច**បានលើកឡើងថា កាលពីឆ្នាំ២០២៤ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបំពេញទស្សនកិច្ចនៅសិង្ហបុរី ហើយនាយករដ្ឋមន្ត្រីសិង្ហបុរី បានអញ្ជើញបំពេញទស្សនកិច្ចនៅកម្ពុជានៅឆ្នាំ២០២៥កន្លងទៅនេះជាគំរូមួយនៃទំនាក់ទំនងដ៏ល្អប្រសើររវាងកម្ពុជានិងសិង្ហបុរី។ លើសពីនេះ **សម្តេច**ក៏បានអរគុណសិង្ហបុរី ចំពោះការចូលរួមចំណែកបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ជាមួយគ្នានោះ **សម្តេចតេជោ** ក៏បានលើកឡើងអំពីបញ្ហាព្រំដែនរវាងកម្ពុជានិងថៃ និងអរគុណសិង្ហបុរីដែលបានចូលរួមចំណែកនិងបញ្ជូនអ្នកសង្កេតការណ៍មកសង្កេតលើបញ្ហាព្រំដែនកម្ពុជានិងថៃ។ **សម្តេច**បានបញ្ជាក់ថា ជំហររបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយថៃ គឺការរក្សានូវបទឈប់បាញ់ឱ្យបាននិងមានប្រសិទ្ធភាពរយៈពេលយូរអង្វែង។ កម្ពុជានៅតែរក្សាការដោះស្រាយបញ្ហាដោយសន្តិវិធី តាមរយៈការចរចាគ្រប់យន្តការដែលភាគីទាំងពីរមាននាពេលកន្លងទៅ។



សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរឱ្យ**ឯកឧត្តមឯកអគ្គរដ្ឋទូត** ទទួលបានជោគជ័យក្នុងឱកាសដែលឯកឧត្តមបានមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសការពូនជ្រំទំនាក់ទំនងរវាងកម្ពុជានិងសិង្ហបុរីឱ្យកាន់តែរីកចម្រើន៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យក្រុមការងារសមាគមជនជាតិខ្មែររស់នៅប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម

នា ព្រឹកថ្ងៃចន្ទ ទី៦ ខែមេសា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យក្រុមការងារសមាគមជនជាតិខ្មែររស់នៅប្រទេសជប៉ុន ដឹកនាំដោយ លោក **ហៃ ឧណ្ណា** ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។



*សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី*

**សម្តេចតេជោ** បានស្វាគមន៍និងអបអរសាទរចំពោះលោក **ហៃ ឧណ្ណា**និងសហការី ដែលបានបង្កើតសមាគមដើម្បីពង្រឹងនូវចំណងសាមគ្គីភាពប្រជាជនខ្មែររស់នៅក្នុងប្រទេសជប៉ុន។

ក្នុងឱកាសនោះ លោក **ហៃ ឧណ្ណា** បានសម្តែងនូវអំណរគុណចំពោះ **សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យរូបលោកនិងសហការី បានជួបសម្តែងការគួរសមនិងរាយការណ៍អំពីវឌ្ឍនភាពរបស់សមាគមជនជាតិខ្មែររស់នៅក្នុងប្រទេសជប៉ុននិងសកម្មភាពការងារមួយចំនួនដែលសមាគមសម្រេចបាន ជាពិសេសគោលដៅក្នុងការពង្រឹងនូវចំណងសាមគ្គីភាពរវាងខ្មែរនិងខ្មែរដែលរស់នៅក្នុងប្រទេសជប៉ុននិងការជួយជ្រោមជ្រែងនៅលើផ្នែកផ្សេងៗទៀត។

**សម្តេចតេជោ** បានសម្តែងនូវការពេញចិត្តចំពោះវឌ្ឍនភាពរបស់សមាគមនិងបានលើកឡើងពាក់ព័ន្ធនឹងការបង្កើតសមាគម គឺជារឿងមួយដ៏លំបាក ក៏ប៉ុន្តែរឿងសំខាន់មួយទៀត គឺការរក្សាបាននូវនិរន្តរភាពសមាគមនេះ។ **សម្តេច**សង្ឃឹមថា សមាគមជនជាតិខ្មែរដែលរស់នៅប្រទេសជប៉ុនដឹកនាំដោយលោក **ហៃ ឧណ្ណា** នឹងរក្សាបាននូវនិរន្តរភាព និងអាចពង្រីកនូវសាមគ្គីភាពនៃសហគមខ្មែរដែលរស់នៅប្រទេសជប៉ុន៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគីយ៉េ ប្រចាំកម្ពុជាចូលជួបសម្តែងការគួរសម និងជម្រាបលា

នាព្រឹកថ្ងៃពុធ ទី៨ ខែមេសា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យលោកជំទាវ Ülkü Kocaefe ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគីយ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

ក្នុងឱកាសនោះ **សម្តេចតេជោ** បានវាយតម្លៃខ្ពស់ចំពោះបេសកកម្មការទូតរបស់**លោកជំទាវឯកអគ្គរដ្ឋទូត** នៅព្រះរាជាណាចក្រកម្ពុជា ដែលសម្រេចបានសមិទ្ធផលជាច្រើនសម្រាប់ការពង្រឹកនូវទំនាក់ទំនងរវាងកម្ពុជានិងតួកគីយ៉េ ដែលមកដល់ពេលនេះប្រទេសទាំងពីរកំពុងតែមានទំនាក់ទំនងដ៏ល្អនិងរីកចម្រើនជាបន្តបន្ទាប់។

នៅក្នុងជំនួបនោះ **លោកជំទាវឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណចំពោះ**សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យលោកជំទាវនិងសហការីចូលជួបសម្តែងការគួរសមនិងជម្រាបលា និងបានរាយការណ៍អំពីសមិទ្ធផលសំខាន់ៗក្នុងអាណត្តិការងាររបស់លោកជំទាវ ដោយបានបង្កើតនូវការិយាល័យតួកគីយ៉េនៅកម្ពុជានិងការបង្កើតនូវជើងហោះហើរតួកគីយ៉េមកកាន់កម្ពុជាកាលពីចុងឆ្នាំ២០២៥។ សមិទ្ធផលដ៏សំខាន់ទាំងនោះ ដើម្បីពង្រឹកនូវទំនាក់ទំនងរវាងកម្ពុជានិងតួកគីយ៉េ ឱ្យកាន់តែរីកចម្រើនទាំងនៅក្នុងក្របខ័ណ្ឌពាណិជ្ជកម្មនិងការផ្សារភ្ជាប់រវាងប្រជាជននឹងប្រជាជន។ ទន្ទឹមនោះ លោកជំទាវក៏បានបង្ហាញអារម្មណ៍ជាប់ចិត្តជាពិសេសគឺស្នាមញញឹមរបស់ប្រជាជនកម្ពុជា និងបានបញ្ជាក់ថា ទោះបីជាលោកជំទាវផុតអាណត្តិជាឯកអគ្គរដ្ឋទូតនៅកម្ពុជា ក៏លោកជំទាវនៅតែជាមិត្តរបស់កម្ពុជាអស់មួយជីវិត។

ជាការឆ្លើយតប **សម្តេចតេជោ** បានសម្តែងនូវក្តីពេញចិត្តយ៉ាងក្រៃលែងចំពោះពាក្យពេចន៍ដ៏មានអត្ថន័យរបស់លោកជំទាវ ចំពោះការពេញចិត្តប្រជាជននិងប្រទេសកម្ពុជា។ **សម្តេច**បានកោតសរសើរអំពីសមិទ្ធផលការងាររបស់លោកជំទាវ ដែលបានខិតខំបង្កើតឱ្យមានការិយាល័យពាណិជ្ជកម្ម វប្បធម៌ និងជើងហោះហើរពីតួកគីយ៉េ ដែលជាចរន្តនៃការគាំទ្រដល់ទំនាក់ទំនងទ្វេភាគីរវាងកម្ពុជានិងតួកគីយ៉េឱ្យកាន់តែល្អប្រសើរ។ **សម្តេចតេជោ** ក៏បានអរគុណតួកគីយ៉េ ចំពោះការគាំទ្រនិងការចូលរួមចំណែក



*លោកជំទាវ Ülkü Kocaefe និងសម្តេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងជម្រាបលា*

ផ្តល់ជំនួយមនុស្សធម៌ដល់ជនភៀសសឹកកម្ពុជា ក្នុងបញ្ហាព្រំដែនកម្ពុជា-ថៃ។ **សម្តេច**បានពន្យល់អំពីបញ្ហាព្រំដែនរវាងកម្ពុជានិងថៃ ឱ្យលោកជំទាវបានជ្រាបផងដែរ ជាពិសេសជំហររបស់កម្ពុជាក្នុងការរក្សានូវបទឈប់បាញ់ឱ្យបានយូរអង្វែងនិងការដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធីតាមរយៈការចរចា។

ជាចុងក្រោយ **សម្តេចតេជោ** បានផ្តាំផ្ញើរបន្ថែមដល់លោកជំទាវបន្តជួយផ្សព្វផ្សាយអំពីសក្តានុពលរបស់កម្ពុជាដល់អ្នកវិនិយោគតួកគីយ៉េ ដើម្បីមកវិនិយោគនិងមកទស្សនាប្រទេសកម្ពុជានិងជូនពរឱ្យលោកជំទាវទទួលបានជោគជ័យជាបន្តបន្ទាប់ទៀត៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ ហ៊ុន សែន ចង់ឃើញកម្ពុជានិងវៀតណាម សម្រេចទំហំពាណិជ្ជកម្មកើនដល់២០ពាន់លានដុល្លារ

ក្នុងឱកាសអនុញ្ញាតឱ្យ ឯកឧត្តម **ត្រិន កឹមទូ** (Tran Cam Tu) សមាជិកការិយាល័យនយោបាយនិងជាសមាជិកប្រចាំការគណៈលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា នាព្រឹកថ្ងៃសុក្រ ទី១០ ខែមេសា ឆ្នាំ២០២៦។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ គឺជាចំណុចស្នូលដ៏សំខាន់នៃទំនាក់ទំនងរវាងកម្ពុជានិងវៀតណាមនិងចង់ឃើញប្រទេសទាំងពីរសម្រេចបាននូវទំហំពាណិជ្ជកម្មកើនដល់២០ពាន់លានដុល្លារអាម៉េរិក ខណៈបច្ចុប្បន្នកំណើនពាណិជ្ជកម្មលើសពី១០ពាន់លានដុល្លារអាម៉េរិករួចទៅហើយ។



*ឯកឧត្តម ត្រិន កឹមទូ និងសម្តេចតេជោ ហ៊ុន សែន*

**សម្តេចតេជោ** បានចាត់ទុកដំណើរទស្សនកិច្ចរបស់សមាជិកការិយាល័យនយោបាយបក្សកុម្មុយនីស្តវៀតណាមមកកាន់ប្រទេសកម្ពុជា គឺបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងដ៏រឹងមាំនិងជានិមិត្តរូបនៃការជឿជាក់គ្នារវាងកម្ពុជានិងវៀតណាម។

នៅក្នុងជំនួបនោះ ឯកឧត្តម **ត្រិន កឹមទូ** បានលើកឡើងអំពីទំនាក់ទំនងសហប្រតិបត្តិការរវាងប្រទេសទាំងពីរមានភាពស្អិតល្មួតនិងរឹងមាំ តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចជាន់ខ្ពស់រវាងថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ។ ឯកឧត្តមបានរំលេចអំពីសហប្រតិបត្តិការរវាងកម្ពុជានិងវៀតណាមលើគ្រប់វិស័យ ជាពិសេសវិស័យការពារជាតិនិងកិច្ចការនៅតាមព្រំដែន ដែលភាគីទាំងពីរបានសហការយ៉ាងមានប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើសឆ្លងដែននិងការពង្រឹងនូវសន្តិសុខនៅតាមព្រំដែន ដែលធ្វើឱ្យព្រំដែនមានសន្តិភាពនិងមានការអភិវឌ្ឍ។ ជាមួយគ្នានោះ ឯកឧត្តមបានបញ្ជាក់អំពីការសាមគ្គីគ្នានិងកិច្ចសហការគ្នាយ៉ាងល្អក្នុងការការពារមិនឱ្យមានកម្លាំងអមិត្តណាមួយ យកទឹកដីនៃប្រទេសទាំងសងខាងដើម្បីប្រឆាំងនឹងប្រទេសម្ខាងទៀត។ លើសពីនេះ ការផ្លាស់ប្តូរទំនិញពាណិជ្ជកម្មតាមព្រំដែនរវាងប្រទេសទាំងពីរបានកើនលើសពី១០ពាន់លានដុល្លារ ហើយប្រទេសទាំងពីរកំពុងតែមានមហិច្ឆតាខិតខំសម្រេចគោលដៅបង្កើនទំហំពាណិជ្ជកម្មឱ្យដល់២០ពាន់លានដុល្លារ។


*ឯកឧត្តម ត្រិន កឹមទូ និងសម្តេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារនិងសម្តែងការគួរសម*

**សម្តេចតេជោ** បានឯកភាពលើការពង្រឹងសហប្រតិបត្តិការនៅតាមព្រំដែនរវាងប្រទេសទាំងពីរ ដើម្បីធានាឱ្យបាននូវព្រំដែនដែលមានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ព្រមទាំងពេញចិត្តចំពោះការលើកឡើងរបស់ឯកឧត្តមអំពីការបង្កើនទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរ។ បន្ថែមពីនេះ **សម្តេច**ក៏បានលើកឡើងអំពីការពង្រឹងសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ ទាំងស្ថាប័ននីតិប្បញ្ញត្តិ ទាំងស្ថាប័នរដ្ឋ ដែលប្រទេសទាំងពីរកំពុងតែពូនជ្រំនិងត្រូវពង្រឹងបន្ថែមទៀតឱ្យកាន់តែស៊ីជម្រៅ។

**សម្តេចតេជោ** បានជំរុញឱ្យភាគីទាំងពីរ ពន្លឿនការបោះបង្គោលព្រំដែនឱ្យបានចប់ជាស្ថាពរ ដោយត្រូវបង្កើនសហការនៅក្នុងការធ្វើកិច្ចការងារដ៏មានសារៈសំខាន់នៅតាមបន្ទាត់ព្រំដែននៃប្រទេសទាំងពីរដែលបានឯកភាពគ្នា។

ឯកឧត្តម **ត្រិន ភីមទូ** បានឯកភាពចំពោះការលើកឡើងរបស់**សម្តេចតេជោ** ក្នុងការជំរុញនិងពន្លឿនការបោះបង្គោលព្រំដែនកម្ពុជានិងវៀតណាម ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននិងបានចាត់ទុកថា ការងារនេះមានសារៈសំខាន់ក្នុងការពង្រឹងសន្តិភាពនិងស្ថិរភាពតាមព្រំដែនរវាងប្រទេសទាំងពីរ ស្របទៅនឹងគោលដៅដែលប្រទេសទាំងពីរមានមិត្តភាពជាប្រពៃណីយូរអង្វែងជាមួយគ្នា។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរឱ្យឯកឧត្តមនិងគណៈប្រតិភូ ទទួលបានជោគជ័យក្នុងការបំពេញទស្សនកិច្ចនៅកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារនិងសម្តែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន ទោះស្ថានភាពពិភពលោកប្រែប្រួលក្តី តែទំនាក់ទំនងកម្ពុជា និងចិនមិនប្រែប្រួលនោះទេ

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់ក្នុងជំនួបពិភាក្សាជាមួយឯកឧត្តម **វ៉ាង យី** (Wang Yi) រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន នាព្រឹក




*ឯកឧត្តម វ៉ាង យី និងសម្តេចតេជោ ហ៊ុន សែន*

ថ្ងៃពុធ ទី២៣ ខែមេសា ឆ្នាំ២០២៦ ថា ទោះបីជាពិភពលោកនៅពេលបច្ចុប្បន្នមានការប្រែប្រួលយ៉ាងណាក្តី ប៉ុន្តែទំនាក់-ទំនងមិត្តភាពរវាងកម្ពុជានិងចិន មិនមានការប្រែប្រួលឡើយ។ ក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្តមរដ្ឋមន្ត្រីការបរទេសនិងឯកឧត្តមរដ្ឋមន្ត្រីការពារជាតិចិនមកកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមកិច្ចសន្ទនាយុទ្ធសាស្ត្រ ២+២ រវាងរដ្ឋមន្ត្រីការបរទេសនិងរដ្ឋមន្ត្រីការពារជាតិកម្ពុជា-ចិន គឺបង្ហាញយ៉ាងច្បាស់អំពីមិត្តភាពដ៏រឹងមាំរវាងកម្ពុជានិងចិន។

ក្នុងឱកាសនោះ ឯកឧត្តម **វ៉ាង យី** បានបង្ហាញក្តីរីករាយដោយបានជួប**សម្តេចតេជោ**ម្តងទៀតនិងជាមិត្តចាស់របស់ចិននិងបាននាំមកនូវការសួរសុខទុក្ខពីឯកឧត្តម **ស៊ី ជិនពីង** ប្រធានាធិបតីចិនចំពោះ**សម្តេចតេជោ** ព្រមទាំងបានដឹងថាថ្មីៗនេះ **សម្តេចតេជោ** បានទៅកាន់ប្រទេសចិនក្នុងការតាមដានអំពីព្រះរាជសុខភាពរបស់ព្រះមហាក្សត្រកម្ពុជា។ ឯកឧត្តមបានបញ្ជាក់ថា រដ្ឋាភិបាលចិនបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការថែព្រះរាជសុខភាពរបស់ព្រះមហាក្សត្រកម្ពុជានិងបានចាត់ទុក**សម្តេចតេជោ** គឺជាតួអង្គដ៏សំខាន់ក្នុងការពង្រឹងនូវចំណងមិត្តភាពរវាងកម្ពុជានិងចិន។ ឯកឧត្តមក៏បានសង្កត់នូវពាក្យថា «មិត្តភាពដែកថែបរវាងកម្ពុជានិងចិន» គឺអាចកើតមានឡើងដោយសារ **សម្តេចតេជោ** ដែលបានខិតខំប្រឹងប្រែងនៅក្នុងការពង្រឹងចំណងមិត្តភាពកន្លងទៅហើយបន្តចំណងមិត្តភាពដោយសម្តេចធិបតី **ហ៊ុន ម៉ាណែត**។ មិត្តភាពដែកថែបនេះ ឯកឧត្តម **ស៊ី ជីនពីង** ធ្លាប់បានបញ្ជាក់ហើយថា មិនមែនមិត្តភាពដែកថែបមានតែឈ្មោះទេ ប៉ុន្តែគឺជាមិត្តភាពដែកថែបដែលបានអនុវត្តជាក់ស្តែងជាមួយគ្នា។

ជាមួយគ្នានោះ ឯកឧត្តម **វ៉ាង យី** បានរាយការណ៍ជូន **សម្តេចតេជោ** ជ្រាបអំពីលទ្ធផលនៃកិច្ចសន្ទនាយុទ្ធសាស្ត្រ ២+២ រវាងរដ្ឋមន្ត្រីការបរទេសនិងរដ្ឋមន្ត្រីការពារជាតិកម្ពុជា-ចិន ដែលបានប្រជុំជជែកពិភាក្សាគ្នា និងបានសម្រេចលទ្ធផលល្អៗជាច្រើនក្នុងការពង្រឹងទៅលើទំនាក់ទំនងទ្វេភាគីរវាងកម្ពុជានិងចិន ឱ្យកាន់តែរឹងមាំបន្ថែមទៀត។

ជាការឆ្លើយតប **សម្តេចតេជោ** បានបង្ហាញការពេញចិត្តយ៉ាងខ្លាំងចំពោះការលើកឡើងរបស់ឯកឧត្តម **វ៉ាង យី** និងបានផ្តាំផ្ញើតាមរយៈឯកឧត្តម ក្នុងការសួរសុខទុក្ខទៅកាន់ឯកឧត្តម **ស៊ី ជិនពីង** ប្រធានាធិបតីចិន ព្រមទាំងអរគុណចំពោះឯកឧត្តមប្រធានាធិបតី ដែលបានសួរសុខទុក្ខដល់**សម្តេច**។

**សម្តេចតេជោ** បានសម្តែងនូវក្តីរីករាយចំពោះលទ្ធផលកិច្ចសន្ទនាយុទ្ធសាស្ត្រ២+២ រវាងរដ្ឋមន្ត្រីការបរទេសនិងរដ្ឋមន្ត្រីការពារជាតិកម្ពុជានិងចិន ដែលបានប្រព្រឹត្តទៅ



*ឯកឧត្តម វ៉ាង យី រដ្ឋមន្ត្រីការបរទេសចិន*



*សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី*

នៅក្នុងប្រទេសកម្ពុជា ហើយ**សម្តេច**សង្ឃឹមថាទំនាក់ទំនងទ្វេភាគីនឹងកាន់តែរឹងមាំបន្ថែមទៀត។ តាមរយៈកិច្ចសន្ទនាយុទ្ធសាស្ត្រនេះ **សម្តេចតេជោ**បានជំរុញទៅកាន់ភាគីចិនសូមឱ្យបន្តការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ **សម្តេច**ក៏បានសង្កត់ធ្ងន់ទៅលើចំណុចស្នូលនៃទំនាក់ទំនង គឺសំដៅទៅលើសេដ្ឋកិច្ចដែលកម្ពុជាចង់ពង្រឹងនូវភាពធន់ឱ្យបានកាន់តែរឹងមាំ។ ជាមួយគ្នានោះ **សម្តេច**ក៏បានអរគុណចំពោះជំនួយរបស់ចិន ជាពិសេសក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចកម្ពុជា។

នៅក្នុងជំនួបនោះផងដែរ ឯកឧត្តម **វ៉ាង យី** បានសរសើរចំពោះភាពរីកចម្រើននៅក្នុងប្រទេសកម្ពុជា ទាំងផ្នែកសេដ្ឋកិច្ចនិងវិស័យផ្សេងៗ ជាពិសេសគឺកម្ពុជាមានអគារខ្ពស់ៗនិងធំៗជាច្រើនដែលកើតមានឡើង។ ឯកឧត្តមបានបញ្ជាក់ថា រដ្ឋាភិបាលចិននៅតែបន្តគាំទ្រការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា ដែលស្របទៅនឹងសហគមន៍ជោគ-វាសនារួមដែលប្រទេសទាំងពីរបានធ្វើជាមួយគ្នានិងដើម្បីផលប្រយោជន៍ប្រជាជននៃប្រទេសទាំងពីរ។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរឱ្យឯកឧត្តម **វ៉ាង យី** និងគណៈប្រតិភូ ឱ្យទទួលបានជោគជ័យក្នុងការបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារនិងសម្តែងការគួរសម*

# គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ចំនួន២

នារសៀលថ្ងៃអង្គារ ទី៣១ ខែមីនា ឆ្នាំ២០២៦ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ មានដូចខាងក្រោម៖

១-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

២-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៣-ផ្សេងៗ។

ក្រោយពីពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានសម្រេចប្រគល់ភារកិច្ចជូន៖



ឯកឧត្តម អ៊ុច បូររិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

១-គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សហការជាមួយគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន នៃព្រឹទ្ធសភា ពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីនាំយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា។

២-គណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដើម្បីនាំយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

# គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាសម្រេចបើកសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ចំនួន២

នាព្រឹកថ្ងៃសុក្រ ទី៣ ខែមេសា ឆ្នាំ២០២៦ វេលាម៉ោង៧:៣០នាទី ឯកឧត្តម **អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤ មានដូចខាងក្រោម៖


*ឯកឧត្តម អ៊ុច បូរិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

**១-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**២-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**៣-កំណត់កាលបរិច្ឆេទនិងរបៀបវារៈប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**៤-ផ្សេងៗ។**

ក្រោយពីពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃដដែល វេលាម៉ោង៨:៣០នាទី ដើម្បីប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ទាំងពីរខាងលើ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន


*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការឆបោក តាមប្រព័ន្ធបច្ចេកវិទ្យានិងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

ផ្អែកតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាព្រឹកថ្ងៃសុក្រ ទី៣ ខែមេសា ឆ្នាំ២០២៦ នៅព្រឹកថ្ងៃដដែល វេលាម៉ោង៨:៣០នាទី ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញដឹកនាំប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៨រូប។ អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន២ ដូចខាងក្រោម៖

**របៀបវារៈទី១៖ ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។**

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងស្របទៅនឹងស្ថានភាព និងការកើនឡើងដែលគួរឱ្យព្រួយបារម្ភ នៃអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានិងមានគោលបំណងកំណត់អំពីវិធានផ្នែកព្រហ្មទណ្ឌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា សំដៅចូលរួមថែរក្សាការពារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនេះ។

សេចក្តីព្រាងច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះបទល្មើសឆបោក ដែលត្រូវបានប្រព្រឹត្តតាមប្រព័ន្ធបច្ចេកវិទ្យា ឬដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយ ដើម្បីប្រព្រឹត្តបទល្មើស ព្រមទាំងចំពោះបទល្មើសដែលពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។



*ឯកឧត្តម អ៊ុច បូររិទ្ធ ប្រធានស្តីទីព្រឹទ្ធសភា*
*និងឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា*

សេចក្តីព្រាងច្បាប់នេះ មានចែងអំពីការបង្កើតឱ្យមានវិធានព្រហ្មទណ្ឌបំពេញចន្លោះខ្វះខាតនៃច្បាប់បច្ចុប្បន្ន ដែលនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមដែលបង្កនូវហានិភ័យធ្ងន់ធ្ងរ ប៉ះពាល់ដល់សន្តិសុខសង្គម សេដ្ឋកិច្ច និងប្រជាពលរដ្ឋ រួមទាំងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះប្រទេសកម្ពុជា ក៏ដូចជាការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា សំដៅចូលរួមថែរក្សាការពារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនេះ។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន៥ជំពូក និង


*លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី ឡើងអានរបាយការណ៍*


*ឯកឧត្តម កើត រិទ្ធ ឡើងការពារសេចក្តីព្រាងច្បាប់*

២៤មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១១២សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។

លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា បានអញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំ អំពីលទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់នេះ និងមានសមាជិកព្រឹទ្ធសភាចំនួន៤រូបឡើងមានយោបល់ ព្រមទាំងមានការឆ្លើយបំភ្លឺពី ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់នេះ ដោយឥតកែប្រែ ចំនួន៥៨សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី២៖ ពិនិត្យហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។**

សេចក្តីស្នើច្បាប់នេះ រៀបចំឡើងសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃការអនុវត្តមុខងារតំណាងរបស់សមាជិកព្រឹទ្ធសភា បង្កភាពងាយស្រួលដល់សមាជិកព្រឹទ្ធសភាធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ផ្តល់ភាពងាយស្រួលក្នុងការផ្តល់ព័ត៌មាន និងគោលនយោបាយនានា ព្រមទាំងក្តាប់បាននូវបញ្ហាប្រឈមនិងឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ មិនតែប៉ុណ្ណោះ ការធ្វើវិសោធនកម្មច្បាប់នេះ ក៏បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីការទទួលខុសត្រូវខ្ពស់របស់អង្គនីតិបញ្ញត្តិក្នុងការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ឱ្យកាន់តែប្រសើរថែមទៀត ដើម្បីជានាសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងធានាឱ្យសមាជិកព្រឹទ្ធសភាអនុវត្តមុខងារតំណាងប្រកបដោយប្រសិទ្ធភាពខ្ពស់។

សេចក្តីស្នើច្បាប់នេះ រៀបចំឡើងមាន២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១១២សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។

លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា បានអញ្ជើញឡើងរាយការណ៍អំពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីស្នើច្បាប់នេះ និងមានសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់ ព្រមទាំងមានការឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា ពីសំណាក់ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា តំណាងក្រុមហត្ថលេខី។



*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា ឡើងការពារសេចក្តីស្នើច្បាប់*

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីស្នើច្បាប់នេះដោយឥតកែប្រែ ចំនួន៥៥សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តច្បាប់*

# ព្រឹទ្ធសភាប្រារព្ធពិធីសូត្រមន្តចម្រើនសិរីមង្គល ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ



ឯកឧត្តម អ៊ុច បូររិទ្ធ និងលោកជំទាវ ចូលរួមក្នុងពិធីសូត្រមន្តចម្រើនសិរីមង្គល ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធពិធីសូត្រមន្តចម្រើនសិរីមង្គល ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងលោកជំទាវ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នារសៀលថ្ងៃពុធ ទី៨ ខែមេសា ឆ្នាំ២០២៦ ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ពិធីសូត្រមន្តចម្រើនសិរីមង្គល បានរៀបចំឡើងដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ បណ្តេញឧបទ្រពពីឆ្នាំចាស់ ប្រោះព្រំថ្វាយព្រះពរជ័យលើករាសី សុំសេចក្តីសុខ សិរីសួស្តី និងទទួលអំណរឆ្នាំថ្មី ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ២៥៧០។

ក្នុងពិធីសូត្រមន្តនេះ ឯកឧត្តម **អ៊ុច បូររិទ្ធ** ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** និងលោកជំទាវ បានអញ្ជើញថ្វាយនូវគ្រឿងសក្ការៈបូជា ទៀន ធូប ផ្កាភ្ញី និងប្រារព្ធកិច្ចនមស្ការព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃសូត្រព្រះធម៌ស្វាធ្យាយ ចម្រើនព្រះបរិត្ត និងពុទ្ធជ័យមង្គលព្រមទាំងវេរប្រគេនទេយ្យទាននិងគ្រឿងបរិក្ខារផ្សេងៗដល់ព្រះសង្ឃ ដើម្បីឧទ្ទិសមហាកុសលផលបុណ្យជូនដល់ដួងវិញ្ញាណក្ខន្ធញាតកាទាំងប្រាំពីរសន្តាន ឥស្សរជន និងវីរយុទ្ធជនដែលបានពលីជីវិត ដើម្បីជាតិមាតុភូមិ ជាពិសេសដល់ដួងវិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** លោកជំទាវ **ញ៉ែម សឿន ជាស៊ីម** សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** ឯកឧត្តម **នៃ ប៉េណា** និងអតីតសមាជិកសមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការដែលបានទទួលមរណកាលទៅកាន់លោកខាងមុខ។



ឯកឧត្តម អ៊ុច បូររិទ្ធ ប្រធានស្តីទីព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា និងលោកជំទាវ



*ទិដ្ឋភាពក្នុងពិធីសូត្រមន្ត ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ*

បន្ទាប់ពីពិធីសូត្រមន្តតាមទំនៀមទម្លាប់ប្រពៃណីព្រះពុទ្ធសាសនាបានចប់សព្វគ្រប់រួចមក ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញទស្សនាការសម្តែងរបាំត្រុដិ ពិសាអាហារសាមគ្គី លេងល្បែងប្រជាប្រិយខ្មែរ និងរាំកម្សាន្ត



យ៉ាងសប្បាយរីករាយ និងស្និទ្ធស្នាលបំផុត។

សូមជម្រាបថា ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ២៥៧០ នឹងប្រព្រឹត្តទៅនាថ្ងៃអង្គារ ដល់ថ្ងៃព្រហស្បតិ៍ ១២រោច ដល់១៤រោច ខែចេត្រ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៦ ដែលមានទេវតាឆ្នាំថ្មីព្រះនាម **«រាក្សសាទេវី»** ជាបុត្រីទី៣ នៃកបិលមហាព្រហ្ម។ សង្ក្រាន្តឆ្នាំថ្មីនេះ នឹងចូលដល់នាវេលាម៉ោង ១០:៤៨នាទី ព្រឹកថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៦៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន





*ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទស្សនាការសម្តែងរបាំ*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នារវាងគណៈកម្មការទី១០ព្រឹទ្ធសភា និងវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា





*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីចុះ MoU រវាងគណៈកម្មការទី១០ព្រឹទ្ធសភានិងវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា*

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា បាន អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសំណេះសំណាលនិង ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) និងវិទ្យាស្ថានបញ្ញាឌីជីថល កម្ពុជា នៅសាលភក្តីរីក្រម១ វិមានព្រឹទ្ធសភា ដោយមាន ការអញ្ជើញចូលរួមពី ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធាន គណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **សុខ សំណាង** ជំនួយការសម្ដេចតេជោប្រធានព្រឹទ្ធសភា សមាជិកខុទ្ទកាល័យ អនុប្រធានទី១ព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងសហការីនៃវិទ្យាស្ថាន បញ្ញាឌីជីថលកម្ពុជា រដ្ឋបាលរាជធានីភ្នំពេញរដ្ឋបាលខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ទូទាំងរាជធានីភ្នំពេញ សរុប ប្រមាណ១៥០នាក់។

អនុស្សរណៈនៃការយោគយល់គ្នាខាងលើ ត្រូវបាន ចុះហត្ថលេខាដោយ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធាន គណៈកម្មការទី១០ព្រឹទ្ធសភា និងលោក **ឈន ឈុនឡេង** ជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ព្រមទាំងជាស្ថាបនិក និងជានាយក វិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា។

ជាកិច្ចចាប់ផ្ដើម ឯកឧត្តម **ម៉ម ប៊ុននាង** បាន សម្ដែងនូវក្ដីសោមនស្សរីករាយ ដោយបានទទួលការ អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ឱ្យចុះអនុស្សរណៈ នៃការយោគយល់គ្នាជាមួយវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ដើម្បីចូលរួមជួយបណ្ដុះបណ្ដាលផ្ដល់ចំណេះដឹង ជំនាញ បច្ចេកទេស និងវិជ្ជាជីវៈជូនកុមារា កុមារី យុវជន យុវនារី និង ប្រជាពលរដ្ឋកម្ពុជា ព្រមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ ដោយ បង្រៀន និងចូលរៀនបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា តាមប្រព័ន្ធនិម្មិត ស្របតាមទិសដៅធំ នៃគោលនយោបាយ អភិវឌ្ឍន៍ឃុំ សង្កាត់។



*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា*

ឯកឧត្តម **ម៉ម ប៊ុននាង** បានគូសបញ្ជាក់ថា តាមរយៈ អនុស្សរណៈនៃការយោគយល់គ្នានេះ គណៈកម្មការទី១០ ព្រឹទ្ធសភា និងវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា បានឯកភាព

ប្រគល់កុំព្យូទ័រលើតុ ឬកុំព្យូទ័រយួរដៃ១គ្រឿង ឬលើសពី១គ្រឿង ជូនឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តភារកិច្ចប្រចាំថ្ងៃ ពិសេសជាប្រយោជន៍ក្នុងការចងក្រងទិន្នន័យប្រជាពលរដ្ឋ ស្ថិតិដែលបម្រើឱ្យការបោះឆ្នោតនាពេលខាងមុខ និងទទួលការចុះបង្រៀនដោយផ្ទាល់របស់វិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា។ ទន្ទឹមនេះ វិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា នឹងផ្តល់អាហារូបករណ៍១០០% សម្រាប់យុវជន យុវនារីចំនួន១០០នាក់ ក្នុងមួយឃុំ សង្កាត់ផងដែរ។

ក្នុងឱកាសនោះ លោក **ឈន ឈុនឡេង** បានធ្វើបទបង្ហាញអំពីបទពិសោធន៍នៃការបណ្តុះបណ្តាលតាមប្រព័ន្ធបច្ចេកវិទ្យារបស់ក្រុមហ៊ុន E-School Cambodia និងឈានទៅបង្កើតវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ដែលមកទល់នឹងពេលនេះ មានអ្នកចូលរួមសិក្សាប្រមាណជាង១លាននាក់។

**ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានថ្លែងនូវការកោតសរសើរនិងគាំទ្រចំពោះគណៈកម្មការទី១០និងវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ដែលបានចាប់ដៃសហការគ្នា ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សមត្ថភាពជីវភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងយុវជន យុវនារី និងកុមារ តាមរយៈការបង្រៀន និងការផ្តល់ឱកាសការងារតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ស្របតាមអាទិភាពគន្លឹះក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលរួមមាន៖ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។

**ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានលើកទឹកចិត្តដល់ភាគីនៃអនុស្សរណៈនេះ ព្រមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបន្តផ្សព្វផ្សាយព័ត៌មានអាហារូបករណ៍ ក៏ដូចជាការចុះ



*លោក ឈន ឈុនឡេង ឡើងធ្វើបទបង្ហាញ*

ឈ្មោះចូលរៀននៅវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ជាពិសេសយុវជន យុវនារីដែលមានជីវភាពខ្វះខាត គ្មានលទ្ធភាព ឬនៅតំបន់ដាច់ស្រយាល ដើម្បីទទួលបាននូវការសិក្សាដែលមានគុណភាពស្តង់ដាអន្តរជាតិនិងមានភាពងាយស្រួលក្នុងការសិក្សា ពិសេសតម្លៃសិក្សាមានកម្រិតទាប ព្រមទាំងអាចរកចំណូលបានក្នុងពេលកំពុងសិក្សា ហើយក៏អាចមានឱកាសទៅបន្តការសិក្សានៅបរទេសថែមទៀតផង។ ឯកឧត្តមបានគូសបញ្ជាក់យ៉ាងច្បាស់ថា មូលដ្ឋានគ្រឹះនៃប្រជាជាតិមួយដ៏រុងរឿងនិងមានការរីកចម្រើនយ៉ាងឆាប់រហ័ស គឺស្ថិតនៅលើភាពសម្បូរបែបនិងគុណភាពនៃធនធានមនុស្ស។ ការចុះអនុស្សរណៈ គឺជាការរួមគ្នាជាធ្លុងមួយ ដើម្បីលើកកម្ពស់ធនធានមនុស្សដែលជាសសរទ្រូងក្នុងការទ្រទ្រង់អនាគតប្រទេសជាតិឱ្យបានរឹងមាំនិងមានការអភិវឌ្ឍលើគ្រប់វិស័យ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា និងថតរូបអនុស្សាវរីយ៍*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីជួបសំណេះសំណាល ប្រគល់ឯកសណ្ឋាន និងសម្ភារៈជូនប្រជាការពារ នៅស្រុកបាធាយ ខេត្តកំពង់ចាម



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាល ប្រគល់ឯកសណ្ឋាន និងសម្ភារៈជូនប្រជាការពារ នៅស្រុកបាធាយ ខេត្តកំពង់ចាម*

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីជួបសំណេះសំណាល និងប្រគល់ឯកសណ្ឋាននិងសម្ភារៈបម្រើការងារសន្តិសុខជូនប្រជាការពារចំនួន ៧៧នាក់ នៅឃុំជើងព្រៃ ស្រុកបាធាយ ខេត្តកំពង់ចាម ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **អ៊ួត ឈាងលី** អភិបាលនៃគណៈអភិបាលស្រុកបាធាយ ព្រមទាំងឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី មន្ត្រីរាជការ ថ្នាក់ដឹកនាំនៃស្រុកបាធាយ កងកម្លាំងប្រដាប់អាវុធ និងប្រជាការពារភូមិ សរុបជាង១០០នាក់។



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាលជាមួយប្រជាការពារ និងអាជ្ញាធរស្រុកបាធាយ ខេត្តកំពង់ចាម*

ក្នុងកិច្ចសំណេះសំណាលនាឱកាសនោះ **ឯកឧត្តមប្រធានស្ដីទីព្រឹទ្ធសភា** បានពាំនាំប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងជម្រាបជូនពីសភាពការណ៍ជុំវិញសកម្មភាពឈ្លានពានរបស់ថៃមកលើបូរណភាពទឹកដីកម្ពុជានិងសុឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធី ដោយផ្អែកលើធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន។

ឯកឧត្តម បានសម្ដែងនូវមោទនភាពជាតិខ្ពស់ចំពោះការរួបរួមសាមគ្គី ឯកភាពជាតិជាធ្លុងមួយរបស់បងប្អូនប្រជាពលរដ្ឋគ្រប់និន្នាការនយោបាយ គ្រប់ស្រទាប់វណ្ណៈទាំងក្នុងនិងក្រៅប្រទេស ជាពិសេសបងប្អូនប្រជាពលរដ្ឋទាំងអស់នៅក្នុងខេត្តកំពង់ចាម ដែលបានផ្ដល់នូវការគាំទ្រទាំងកម្លាំងកាយ ចិត្ត និងសម្ភារៈដល់វីរយុទ្ធជននៅសមរភូមិ និងបងប្អូនប្រជាជនភៀសសឹក ព្រមទាំងបានអំពាវនាវ



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

ដល់បងប្អូនខ្មែរទាំងអស់បន្តរួបរួមសាមគ្គី ឯកភាពជាតិជាធ្លុងមួយ និងមានជំនឿជឿជាក់លើការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចតេជោ** ប្រធានព្រឹទ្ធសភានិងសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីកម្ពុជាក្នុងការចាត់វិធានការការពារបូរណភាពទឹកដី សុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ។

ឯកឧត្តម បានផ្ដាំផ្ញើដល់អាជ្ញាធរនិងបងប្អូនប្រជា-ពលរដ្ឋទាំងអស់នៅមូលដ្ឋាន ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះរោហារសាស្ត្រអុជអាលបំបែកបំបាក់សង្គមជាតិរបស់ជនអគតិមួយចំនួន ជាពិសេសសកម្មភាពរបស់ជនក្បត់តជំនាន់ ព្រមទាំងពង្រឹងមហាសាមគ្គីជាតិកាន់តែរឹងមាំថែមទៀត នៅក្នុងកាលៈទេសៈដែលប្រទេសជាតិមាតុភូមិកំពុងប្រឈមនឹងហានិភ័យនៃការឈ្លានពានរបស់ប្រទេសថៃ។

នៅទីបញ្ចប់ **ឯកឧត្តមប្រធានស្ដីទីព្រឹទ្ធសភា** ក៏បានលើកឡើងអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់តម្លៃប្រេងដែលកំពុងហក់ឡើង ដែលបង្កឡើងដោយសង្គ្រាមនៅមជ្ឈិមបូព៌ានិងអំពាវនាវដល់ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក បន្តអនុវត្តអនុក្រឹត្យលេខ០៣ របស់រាជរដ្ឋាភិបាលស្ដីពីការគ្រប់គ្រងសន្តិសុខ សុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្ដុំ ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប និងបោសសម្អាតបទល្មើសនានា ជាពិសេសបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ (Online Scams) និងបញ្ហាគ្រឿងញៀន៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយប្រជាការពារ និងអាជ្ញាធរស្រុកបាធាយ ខេត្តកំពង់ចាម*

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជួបពិភាក្សាការងារជាមួយគណៈប្រតិភូសភាឡាវ រូម៉ានី និងម៉ារុក ក្នុងអំឡុងមហាសន្និបាតលើកទី១៥២ នៃសហភាពអន្តរសភា (IPU)



*ឯកឧត្តម អ៊ុច បូរិទ្ធ ជួបពិភាក្សាទ្វេភាគីជាមួយលោកជំទាវបណ្ឌិត សួនថូន សាយ៉ាចាក់*



នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦ ក្នុងឱកាសនៃមហាសន្និបាតលើកទី១៥២ នៃសហភាពអន្តរសភា (IPU) ទីក្រុងអ៊ីស្តង់ប៊ុល ប្រទេសតួកគីយ៉េ ឯកឧត្តម **អ៊ុច បូរិទ្ធ** បានអញ្ជើញជួបពិភាក្សាទ្វេភាគីជាមួយ លោកជំទាវបណ្ឌិត **សួនថូន សាយ៉ាចាក់** (Sounthone Xayachack) អនុប្រធានរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនិងជាប្រធានគណៈប្រតិភូសភាឡាវ។ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះមិត្តភាពជាប្រពៃណីនិងភាពជាអ្នកជិតខាងល្អរវាងកម្ពុជានិងឡាវ ហើយបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្ត ក្នុងការបន្តពង្រឹងសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញត្តិទាំងពីរ រួមទាំងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ច កិច្ចសន្ទនា ការចែករំលែកបទពិសោធ និងកិច្ចសហការក្នុងក្របខ័ណ្ឌពហុភាគី។



*ឯកឧត្តម អ៊ុច បូរិទ្ធ ជួបពិភាក្សាការងារជាមួយឯកឧត្តម Miklos Zolta*

ដោយឡែក នៅព្រឹកថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូសភាកម្ពុជា អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម Miklos Zoltan ប្រធានគណៈប្រតិភូសភារូម៉ានី។

ក្នុងបរិយាកាសប្រកបដោយមិត្តភាព និងភាពស្និទ្ធស្នាល។ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងយូរអង្វែង និងសហប្រតិបត្តិទ្វេភាគីដែលផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកនិងបានផ្លាស់ប្តូរយោបល់លើបញ្ហាក្នុងតំបន់ និងអន្តរជាតិ ដែលជាបញ្ហាប្រឈមរួម។ ភាគីទាំងពីរបានយល់ស្របគ្នាថា ប្រទេសទាំងពីរមានសក្តានុពលខ្លាំងក្នុងការលើកកម្ពស់ទំនាក់ទំនងរវាងប្រទេសនិងប្រជាជនទាំងពីរ តាមរយៈការជំរុញសហប្រតិបត្តិការ នយោបាយ ពាណិជ្ជកម្ម វិនិយោគ ថាមពល ហេដ្ឋារចនាសម្ព័ន្ធ អប់រំ និងការងារ។ ភាគីទាំងពីរក៏បានឯកភាពពង្រឹងសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ តាមរយៈការផ្លាស់ប្តូរទស្សនកិច្ច កិច្ចសន្ទនា ការចែករំលែកបទពិសោធ ការគាំទ្រគ្នាក្នុងការងារអន្តរសភា និងការរៀបចំ និងចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី ការពង្រឹងសហប្រតិបត្តិការសភា។

ក្នុងថ្ងៃដដែលនោះ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានអញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តម Mohamed Ould Errachid ប្រធានសភាទីប្រឹក្សា នៃព្រះរាជាណាចក្រម៉ារ៉ុក។ កិច្ចជំនួបនេះ ភាគីទាំងពីរបានប្តេជ្ញាបន្តពង្រឹងកិច្ចសន្ទនាសភានិងពង្រីកសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជានិងម៉ារ៉ុក និងបានបញ្ជាក់សាជាថ្មីនូវមិត្តភាពយូរអង្វែង និងការគោរពគ្នាទៅវិញទៅមក រវាងព្រះរាជាណាចក្រទាំងពីរ ព្រមទាំងបានគូសបញ្ជាក់អំពីបំណងរួមក្នុងការបើកទិសដៅថ្មីៗនៃកិច្ចសហប្រតិបត្តិការ។ ភាគីទាំងពីរក៏បានលើកឡើងអំពីអត្ថន័យពិសេសនៃឆ្នាំ២០២៦ ដែលជាខួបលើកទី៣០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ហើយបានផ្លាស់ប្តូរទស្សនៈអំពីមធ្យោបាយនានា ក្នុងការពង្រឹងការចូលរួមរវាងសភា ជំរុញការផ្លាស់ប្តូរទស្សនកិច្ចនិងជំនាញ ព្រមទាំងពង្រឹងការសម្របសម្រួលនៅក្នុងវេទិកាសភាតំបន់និងអន្តរជាតិ។ នៅចុងបញ្ចប់នៃកិច្ចប្រជុំ ភាគីទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីសហប្រតិបត្តិការសភារវាងព្រឹទ្ធសភាកម្ពុជានិងសភាទីប្រឹក្សា នៃព្រះរាជាណាចក្រម៉ារ៉ុក ដែលជាចំណុចសំខាន់មួយក្នុងទំនាក់ទំនងទ្វេភាគីនិងបើកទំព័រថ្មីនៃសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ៕




*ឯកឧត្តម អ៊ុច បូរិទ្ធ ជួបពិភាក្សាការងារជាមួយឯកឧត្តម Mohamed Ould Rachid និងចុះ MoU រវាងព្រឹទ្ធសភាកម្ពុជានិងសភាម៉ារ៉ុក*

ប្រភព៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជួបពិភាក្សាការងារជាមួយប្រធានរដ្ឋសភាជាតិតួកគីយ៉េ និងគណៈប្រតិភូជាន់ខ្ពស់នៃសភាជាតិហុងគ្រី ក្នុងអំឡុងមហាសន្និបាត IPU លើកទី១៥២



*ឯកឧត្តម អ៊ុច បូររិទ្ធ ជួបពិភាក្សាការងារទ្វេភាគីជាមួយឯកឧត្តម Numan Kurtulmuş*

ទីក្រុងអ៊ីស្តង់ប៊ុល៖ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តម Numan Kurtulmuş ប្រធានរដ្ឋសភាជាតិតួកគីយ៉េ។ ក្នុងកិច្ចសន្ទនា ឯកឧត្តម Numan Kurtulmuş បានស្វាគមន៍ការចូលរួមរបស់គណៈប្រតិភូកម្ពុជា ក្នុងមហាសន្និបាត IPU និងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការរក្សាទំនាក់ទំនងជាប្រចាំរវាងក្រុមមិត្តភាពសភានៃប្រទេសទាំងពីរ។

ភាគីទាំងពីរក៏បានលើកឡើងពីការរីកចម្រើននៃទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការតភ្ជាប់រវាងប្រជាជននៃប្រទេសទាំងពីរ រួមទាំងការហោះហើរត្រង់របស់ក្រុមហ៊ុន Turkish Airlines មកកាន់រាជធានីភ្នំពេញ ការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជា សកម្មភាពរបស់មជ្ឈមណ្ឌលវប្បធម៌ Yunus Emre និងការចូលរួមរបស់ទីភ្នាក់ងារ TİKA ក្នុងគម្រោងមនុស្សធម៌នៅកម្ពុជា។



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញថតរូបអនុស្សាវរីយ៍*

ក្នុងជំនួបនោះ ឯកឧត្តម **អ៊ុច បូររិទ្ធ** បានអបអរសាទររដ្ឋសភាជាតិតួកគីយ៉េចំពោះការរៀបចំមហាសន្និបាត IPU លើកទី១៥២ ប្រកបដោយជោគជ័យនិងបានថ្លែងអំណរគុណចំពោះបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅដែលបានផ្តល់ជូនគណៈប្រតិភូកម្ពុជា។ បន្ថែមពីនេះ ឯកឧត្តមបានលើកឡើងពីសក្តានុពលនៃការពង្រឹងសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ តាមរយៈក្រុមមិត្តភាពសភានិងការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់។ ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុច បូររិទ្ធ** បានអញ្ជើញឯកឧត្តម Numan Kurtulmuş ចូលរួមកិច្ចប្រជុំប្រធានសភាអន្តរសភាលើកទី២ ដែលកម្ពុជាគ្រោងរៀបចំនៅពេលខាងមុខផងដែរ។



*ឯកឧត្តម អ៊ុច បូរិទ្ធ ជួបពិភាក្សាការងារទ្វេភាគីជាមួយលោកជំទាវ Márta MÁTRAI*

ដោយឡែក នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូរិទ្ធ** បានជួបពិភាក្សាការងារទ្វេភាគីជាមួយលោកជំទាវ Márta MÁTRAI អនុប្រធានទី១រដ្ឋសភាហុងគ្រី។ ជំនួបនេះ បានប្រព្រឹត្តទៅក្នុងបរិយាកាសកក់ក្តៅ ស្និទ្ធស្នាល និងស្ថាបនា ដោយឆ្លុះបញ្ចាំងពីមិត្តភាពជាប្រពៃណីនិងសហប្រតិបត្តិការល្អរវាងកម្ពុជានិងហុងគ្រី។

ឯកឧត្តម **អ៊ុច បូរិទ្ធ** បានសម្តែងនូវការដឹងគុណចំពោះជំនួយឧបត្ថម្ភដ៏មានតម្លៃរបស់រដ្ឋាភិបាលនិងប្រជាជនហុងគ្រីដល់កម្ពុជា ក្រោយការរំដោះប្រទេសក្នុងឆ្នាំ១៩៧៩ ជាពិសេសលើវិស័យអប់រំ អាហារូបករណ៍ និងសុខាភិបាល និងបានបញ្ជាក់ថា កម្ពុជានឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយហុងគ្រីក្នុងក្របខ័ណ្ឌនៃការទូតសភា ដើម្បីពង្រឹងមិត្តភាព និងជំរុញការអភិវឌ្ឍជាតិ។

ជាការឆ្លើយតប លោកជំទាវ Márta MÁTRAI ក៏បានលើកឡើងអំពីការរីកចម្រើននៃសហប្រតិបត្តិការលើវិស័យអប់រំ ជាពិសេសកម្មវិធី Stipendium Hungaricum នឹងផ្តល់អាហារូបករណ៍បន្ថែមរហូតដល់ ៣០កន្លែងសម្រាប់និស្សិតកម្ពុជា និងបានស្វាគមន៍អនុស្សរណៈនៃការយោគយល់និងកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានសភានៃប្រទេសទាំងពីរ ដែលត្រូវបានចុះហត្ថលេខាកន្លងមកដោយចាត់ទុកថា ជាមូលដ្ឋានសំខាន់សម្រាប់ការពង្រឹងសហប្រតិបត្តិការស្ថាប័នទៅមុខទៀត។

ឯកឧត្តម **អ៊ុច បូរិទ្ធ** បានលើកឡើងអំពីសារៈសំខាន់នៃការពង្រឹងយន្តការក្រុមមិត្តភាពសភាកម្ពុជា-ហុងគ្រីនិងការចូលរួមរបស់ព្រឹទ្ធសភាកម្ពុជា ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការនេះ ដើម្បីជាឱកាសសម្រាប់ស្ថាប័នជាមិត្តទាំងពីរអាចធ្វើការផ្លាស់ប្តូរព័ត៌មាន ទស្សនៈ និងបទពិសោធជាប្រចាំ។ ភាគីទាំងពីរក៏បានបង្ហាញការយកចិត្តទុកដាក់ជាពិសេសចំពោះការប្រារព្ធខួបលើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជានិងហុងគ្រីនៅឆ្នាំនេះនិងបានឯកភាពថា គួររៀបចំសកម្មភាពសមស្របនានា ដើម្បីអបអរសាទរឱកាសដ៏មានអត្ថន័យនេះ។

ជំនួបទ្វេភាគីទាំងពីរនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីតួនាទីសកម្មរបស់ព្រឹទ្ធសភាកម្ពុជា ក្នុងការជំរុញការទូតសភា ពង្រឹងមិត្តភាពជាមួយបណ្តាប្រទេសជាមិត្ត និងពង្រីកសហប្រតិបត្តិការលើវិស័យជាច្រើនសម្រាប់ផលប្រយោជន៍រួមនៃប្រទេសនិងប្រជាជន៕

ប្រភព៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

# កម្ពុជាប្តេជ្ញាចិត្តខ្ពស់ក្នុងការលុបបំបាត់បទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីការពារសុវត្ថិភាពពលរដ្ឋ និងកិត្យានុភាពជាតិ




*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញជាអធិបតីក្នុងពិធីធ្វើបទបង្ហាញ ស្តីពី «ការបោសសម្អាតនិងប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) នៅកម្ពុជា»*

នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ នៅវិមានសាមគ្គីភាព ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីធ្វើបទបង្ហាញស្តីពី «ការបោសសម្អាតនិងប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា(Online Scams) នៅកម្ពុជា»។ ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** បានសង្កត់ធ្ងន់លើចំណុចគន្លឹះសំខាន់ៗ ដូចខាងក្រោម៖



-ត្រូវបញ្ជាក់ឱ្យច្បាស់ថា «ប្រជាជនកម្ពុជាមិនមែនជាឧក្រិដ្ឋជនទេ ប៉ុន្តែកម្ពុជា គឺជាប្រទេសរងគ្រោះដោយសារឧក្រិដ្ឋជនបរទេសបានលួចជ្រកកោនប្រើប្រាស់ទឹកដីកម្ពុជាធ្វើសកម្មភាពខុសច្បាប់»។

-គិតចាប់ពីខែមិថុនា រហូតដល់ដើមឆ្នាំ២០២៦ សមត្ថកិច្ចបានបង្ក្រាបបទល្មើស Online Scams យ៉ាងហោចណាស់ ២០០ករណី នៅទីតាំងប្រមាណ២.៥០០កន្លែង។ ជាលទ្ធផលជនបរទេសពាក់ព័ន្ធប្រមាណ២១ម៉ឺននាក់ បានចាកចេញពីកម្ពុជា និង៨.០០០នាក់ ត្រូវបានបណ្តេញចេញតាមនីតិវិធីច្បាប់។



*ទិដ្ឋភាពក្នុងពិធីធ្វើបទបង្ហាញ ស្តីពី «ការបោសសម្អាតនិងប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) នៅកម្ពុជា»*

-បទបង្ហាញនេះ ផ្តល់ទិន្នន័យសំខាន់សម្រាប់ព្រឹទ្ធសភា ក្នុងការពិនិត្យនិងផ្តល់យោបល់លើ «សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា» ដើម្បីក្លាយជាអាវុធគតិយុត្តដ៏រឹងមាំក្នុងការផ្តន្ទាទោសរាល់មេខ្លោងនិងអ្នកពាក់ព័ន្ធ។

-អំពាវនាវឱ្យមានការបន្តពង្រឹងការអនុវត្តច្បាប់ សហប្រតិបត្តិការអន្តរជាតិ ជាពិសេសជាមួយ FBI, UNODC បណ្តាប្រទេសមេគង្គ-ឡានឆាង( LMC ) និងដៃគូអន្តរជាតិ និងជំរុញការអប់រំផ្សព្វផ្សាយដល់ពលរដ្ឋឱ្យយល់ដឹងពីល្បិចកលបោកប្រាស់ ដែលវិវត្តលឿននិងថ្មីៗ។

ជាទីបញ្ចប់ **ឯកឧត្តមបណ្ឌិត** បានលើកទឹកចិត្ត ឱ្យសមាជិកព្រឹទ្ធសភា និងរដ្ឋសភា យកចិត្តទុកដាក់បញ្ហាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងជួយតាមដាន ផ្តល់ព័ត៌មានដល់អាជ្ញាធរ ដើម្បីបោសសម្អាតបទល្មើសឆបោកនេះ។ ក្រោមការដឹកនាំផ្ទាល់របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និងការគាំទ្រពីស្ថាប័ននីតិប្បញ្ញត្តិ កម្ពុជានឹងទទួលបានជោគជ័យក្នុងការលុបបំបាត់បទល្មើសឆបោកបច្ចេកវិទ្យា ដើម្បីសុវត្ថិភាពពលរដ្ឋ និងកិត្យានុភាពជាតិ៕





*សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា ចូលរួមពិធីធ្វើបទបង្ហាញ នៅវិមានសាមគ្គីភាព*

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញថតរូបអនុស្សាវរីយ៍*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៦ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព សិលាភិរ័ក្ខសិរីវិសុទ្ធា អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ផូ គួច** ម្ដាយបង្កើតរបស់ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនគរបាលជាតិ។






❈នារសៀលថ្ងៃចន្ទ ទី៦ ខែមេសា ឆ្នាំ២០២៦ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **អ៊ុក សាផន** បងស្រីបង្កើតរបស់លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា។

❈នារសៀលថ្ងៃព្រហស្បតិ៍ ទី៩ ខែមេសា ឆ្នាំ២០២៦ គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព សិលាភិរ័ក្ខសិរីវិសុទ្ធា អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ផូ គួច** ម្ដាយបង្កើតរបស់ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនគរបាលជាតិ។






❈នារសៀលថ្ងៃទី១៣ និងថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ទៅចូលរួមនិងធ្វើមាតុភូមិនិវត្តន៍ពីមហាសន្និបាតសហភាពអន្តរសភា លើកទី១៥២ និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងអ៊ីស្តង់ប៊ុល ប្រទេសតួកគីយ៉េ។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃ ទី២២ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដើម្បីពិនិត្យ ពិភាក្សាលើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី១ ដល់លើកទី៥, រៀបចំរបាយការណ៍ បញ្ហាប្រឈម និងសំណូមពរ ដែលទទួលបានពីក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលកន្លងមក ជូនថ្នាក់ដឹកនាំព្រឹទ្ធសភានិងរៀបចំកម្មវិធីសំណេះសំណាលនាពេលខាងមុខ នៅបន្ទប់ប្រជុំឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែមេសា ឆ្នាំ២០២៦ នៅបន្ទប់ប្រជុំឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភានិងជាប្រធានក្រុមសភាជាតិកម្ពុជា-APF និងជាអនុប្រធានសភាប្រើភាសាបារាំង (APF) បានដឹកនាំកិច្ចប្រជុំត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង (APF) និងសិក្ខាសាលាស្តីពី «ក្របខ័ណ្ឌនិងការប្រើប្រាស់ឌីជីថលនិងបញ្ញាសិប្បនិម្មិតនៅក្នុងសភា» នៅខេត្តសៀមរាប។



❈នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាប្រធានគណៈកម្មការពិសេស បានដឹកនាំគណៈប្រតិភូគណៈកម្មការពិសេសព្រឹទ្ធសភា អញ្ជើញការពារសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅវិមានរដ្ឋសភា។



❈នារសៀលថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ខុទ្ទកាល័យក្នុងរយៈពេល១ឆ្នាំ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាល្ងាចថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ដែលរៀបចំដោយសមាគមអតីតនិស្សិតខ្មែរមកពីជប៉ុន (JAC) នៅសណ្ឋាគារ Raffles Le Royal រាជធានីភ្នំពេញ។





❈នារសៀលថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំជាមួយក្រុមសមាជិកភូមិភាគទាំង៨ គណៈកម្មការជំនាញទាំង១០ ក្រុមសមាជិកា និងគណៈកម្មការក្រមសីលធម៌សភា នៃព្រឹទ្ធសភា ដើម្បីបូកសរុបលទ្ធផលការងារចន្លោះសម័យប្រជុំលើកទី៤និងទី៥ នៃព្រឹទ្ធសភា នីតិកាលទី៥ នៅសាលភក្តីវិក្រម៣ វិមានព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១និងលោកជំទាវ រួមជាមួយឯកឧត្តម និងលោកជំទាវក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពអគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **អ៊ុក សាផន** បងស្រីបង្កើតរបស់លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា។





❈នាថ្ងៃអង្គារ ទី៧ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់និងប្រជាពលរដ្ឋព្រមទាំងនាំយកទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងចង្ហាន់ប្រគេនព្រះសង្ឃ នៅវត្តអម្ពផល (ហៅវត្តចុងកោះ) សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្តសង្ក្រាន្តឆ្នាំថ្មីនិងសំណេះសំណាលជាមួយថ្នាក់ដឹកនាំ លោកគ្រូ អ្នកគ្រូ មន្ត្រីរាជការ និងនិស្សិតនៃវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប។





❈នារសៀលថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិព័រណ៌ផលិតផលខ្មែរ ក្រោមប្រធានបទរួមគ្នាផលិតនិងរួមគ្នាប្រើផលិតផលជាតិខ្មែរ នៅអគារពាណិជ្ជកម្មកោះពេជ្រ រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា អមដំណើរដោយទីប្រឹក្សា ជំនួយការ និងសហការី បានអញ្ជើញចូលជួបសម្តែងការគួរសមនិងគោរពជូនពរឯកឧត្តម **អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នៅបន្ទប់ប្រជុំឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នៅវត្តសូរិយាពោធិមាស (វត្តក្តីចាស់) ស្ថិតក្នុងសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ។

❈នារសៀលថ្ងៃព្រហស្បតិ៍ ទី១៦ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ថៃ អ៊ីខហ៊ាង** ម្តាយក្មេករបស់ឯកឧត្តម **ប្រាក់ ដាវីដ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៕



# គណៈកម្មការទី៨ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនសមាគមស្នាមញញឹមថ្មីនៃក្តីសង្ឃឹមរបស់កុមារ



*លោកជំទាវ មាន សំអាន មានប្រសាសន៍សំណេះសំណាល*

គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា (គណៈកម្មការទី៨) និងក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការនិងជាប្រធានក្រុម បានអញ្ជើញចុះសួរសុខទុក្ខ លោកគ្រូ អ្នកគ្រូស្ម័គ្រចិត្ត និងកុមារ ព្រមទាំងនាំយកអំណោយជូនសមាគមស្នាមញញឹមថ្មីនៃក្តីសង្ឃឹមរបស់កុមារ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាព្រឹកថ្ងៃសុក្រ ទី១០ ខែមេសា ឆ្នាំ២០២៦។

ក្នុងឱកាសនោះ **លោកជំទាវប្រធាន** បាននាំយកនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខប្រកបដោយការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** និងថ្នាក់ដឹកនាំព្រឹទ្ធសភា ព្រមទាំងបានថ្លែងកោតសរសើរចំពោះសមាគមដែលខិតខំប្រឹងប្រែង និងអភិវឌ្ឍន៍ឱ្យមានការរីកចម្រើនជាលំដាប់ ជាពិសេសផ្តល់ការថែទាំ អាហារ ការស្នាក់នៅ និងបញ្ជូនកុមារទៅសាលារៀនយ៉ាងទៀងទាត់ បង្ហាត់បង្រៀនកុមារមានទម្លាប់រស់នៅល្អ មានវិន័យ និងសុជីវធម៌ ព្រមទាំងស្វះស្វែងចូលរួមក្នុងកិច្ចការសង្គមផ្សេងៗ។

**លោកជំទាវប្រធាន** បានលើកឡើងថា កុមារគឺជាទំពាំងស្នងឫស្សី ដែលចាំបាច់ត្រូវយកចិត្តទុកដាក់មើលថែទាំឱ្យបានល្អ ដ្បិតពួកគាត់គួរឱ្យអាណិតណាស់ដែលគ្មានអាណាព្យាបាលមើលថែ ប៉ុន្តែជាបុណ្យកុសលល្អដែលមានសមាគមបានយកមកចិញ្ចឹមបីបាច់ថែរក្សា ផ្តត់ផ្តង់ការរៀនសូត្រ ផ្តល់ចំណីអាហារ កន្លែងស្នាក់នៅជាដើម ដែលសបញ្ជាក់នូវការរួមចំណែកជួយសង្គមយើងទាំងអស់គ្នាតាមរូបភាពផ្សេងៗក្នុងទិសដៅរក្សាសន្តិភាពនិងការអភិវឌ្ឍជាតិឱ្យរីកចម្រើនទៅមុខជាលំដាប់។

**លោកជំទាវប្រធាន** បានណែនាំដល់ក្មួយៗ ចៅៗ និងកុមារទាំងអស់ ត្រូវចេះថែទាំសុខភាពឱ្យបានល្អ ទម្លាប់ហូប



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

ស្អាត និងផឹកទឹកដាំឆ្អិន ហើយត្រូវចេះស្រឡាញ់ សាមគ្គីគ្នា ជួយគ្នាទៅវិញទៅមក និងត្រូវចៀសឱ្យឆ្ងាយពីការសេពគប់មិត្តមិនល្អ ឬការប្រើប្រាស់គ្រឿងញៀន ហើយត្រូវខិតខំសិក្សារៀនសូត្រឱ្យពូកែ ដើម្បីអនាគតរុងរឿង ក្លាយជាពលរដ្ឋល្អ និងជាធនធានមនុស្សដ៏ឆ្នើមរបស់សង្គមជាតិ។



*លោកជំទាវ មាន សំអាន ទទួលលិខិតថ្លែងអំណរគុណពី សមាគមស្នាមញញឹមថ្មីនៃក្តីសង្ឃឹមរបស់កុមារ*

អំណោយដែលគណៈកម្មការទី៨ព្រឹទ្ធសភានិងក្រុមសមាជិកាព្រឹទ្ធសភា បានផ្តល់ជូនសម្រាប់សម្រាលជីវភាពរស់នៅប្រចាំថ្ងៃរបស់មណ្ឌលរួមមាន៖ ១-ទឹកបរិសុទ្ធចំនួន៣០កេស ២-ទឹកក្រូចចំនួន៥កេស ៣-ទឹកផ្លែឈើចំនួន៥កេស ៤-ផ្លែក្រូចក្រហមចំនួន១០កេស ៥-ផ្លែសារីចំនួន៤កេស ៦-ថវិកាឧបត្ថម្ភមណ្ឌលចំនួន១លានរៀល និង៧-ថវិកាឧបត្ថម្ភកុមារក្នុងមណ្ឌលចំនួន១៣៥នាក់ ដោយក្នុងម្នាក់ៗទទួលបានចំនួន១ម៉ឺនរៀល៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍*

# ឯកឧត្តម ម៉ម ប៊ុននាង អញ្ជើញនាំយកអំណោយមនុស្សធម៌ ក្នុងទំហំទឹកប្រាក់ ប្រមាណជាងមួយលានប្រាំសែនដុល្លារអាមេរិក ប្រគល់ជូនរដ្ឋបាលខេត្តស្វាយរៀង


ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា


ឯកឧត្តម ប៉េង ពោធិ៍សា អភិបាលខេត្តស្វាយរៀង

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ គណៈប្រតិភូគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយមនុស្សធម៌ដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** រួមជាមួយអំណោយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ Global Life Sharing និងអំណោយរបស់វិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ប្រគល់ជូនរដ្ឋបាលខេត្តស្វាយរៀង នៅសាលាខេត្តស្វាយរៀង។

អំណោយមនុស្សធម៌ ដែលប្រគល់ជូនរដ្ឋបាលខេត្តស្វាយរៀងនាឱកាសនោះ រួមមាន៖ ឱសថសម្រាប់ព្យាបាលជំងឺទូទៅ រួមជាមួយកុំព្យូទ័រយួរដៃចំនួន១៣គ្រឿង ដើម្បីចូលរួមលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះឱ្យបានកាន់តែប្រសើរ ព្រមទាំងចូលរួមលើកកម្ពស់ការអប់រំថ្នាក់ឧត្តមសិក្សាតាមប្រព័ន្ធឌីជីថលដល់យុវជន ជាពិសេសដល់អ្នកដែលពុំមានលទ្ធភាព និងពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សា។



ទិដ្ឋភាពក្នុងពិធីប្រគល់អំណោយមនុស្សធម៌

មានប្រសាសន៍សំណេះសំណាលនាឱកាសនោះ **ឯកឧត្តមប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា** បាននាំនូវបណ្តាំសួរសុខទុក្ខ ប្រកបដោយសេចក្តីនឹករលឹកពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់ថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ជាពិសេសប្រជាពលរដ្ឋទូទាំងខេត្តស្វាយរៀង។ ឯកឧត្តមមានប្រសាសន៍បន្តថា ព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានកំណត់យកអាទិភាពការងារចម្បងចំនួនពីរ គឺ១-ការរួមប្រាស្រ័យឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោត តាមរយៈការចុះគាំទ្រកិច្ចអភិវឌ្ឍនៅមូលដ្ឋាន និង២-ការពង្រឹងកិច្ចអនុវត្តការទូតសភា។ ហើយពេលនេះ ក្នុងនាមជាសេនាធិការរបស់ព្រឹទ្ធសភា គណៈកម្មការទី១០ បាននាំមកនូវសមិទ្ធផលនៃការអនុវត្តការងារជាអាទិភាពទាំងពីរខាងលើដែលមានទឹកប្រាក់សរុបប្រមាណជាងមួយលានប្រាំសែនដុល្លារ ជូនដល់រដ្ឋបាលខេត្តស្វាយរៀង។

ក្នុងឱកាសនោះ លោក **ឈន ឈុនឡេង** ជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ព្រមទាំងជាស្ថាបនិក និងជានាយកវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ក៏បានធ្វើបទបង្ហាញអំពីដំណើរការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន E-School Cambodia និងវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ព្រមទាំងផ្តល់អាហារូបករណ៍ចំនួន១០០កន្លែង (ក្នុងមួយឃុំ សង្កាត់) សិក្សាដោយឥតគិតថ្លៃ ជូនដល់យុវជនក្នុងខេត្តស្វាយរៀង តាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់។

តាងនាមរដ្ឋបាលខេត្ត និងប្រជាពលរដ្ឋទូទាំងខេត្តស្វាយរៀងឯកឧត្តម **ម៉េន ពោធិ៍សា** អភិបាលខេត្តស្វាយរៀង បានមានប្រសាសន៍ថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា ថ្នាក់ដឹកនាំព្រឹទ្ធសភា ជាពិសេសគណៈកម្មការទី១០ព្រឹទ្ធសភា មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ព្រមទាំងវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ដែលបាននាំយកអំណោយមនុស្សធម៌ដ៏ថ្លៃថ្លានិងមានសារៈសំខាន់បំផុត មកប្រគល់ជូនដល់រដ្ឋបាលខេត្តស្វាយរៀង និងជាពិសេសចំពោះយុវជនឱ្យទទួលបាននូវការសិក្សាកាន់តែងាយស្រួល ចំណាយតិចតែមានប្រសិទ្ធភាពនិងគុណភាពតាមស្តង់ដាអន្តរជាតិ។ ឯកឧត្តមបានប្តេជ្ញាគ្រប់គ្រងបែងចែកអំណោយរបស់ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ឱ្យដល់ដៃអាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព បរិយាបន្ន និងផ្សព្វផ្សាយការបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថលរបស់វិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា ឱ្យបានដល់គ្រប់មូលដ្ឋានក្នុងខេត្តស្វាយរៀង៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពប្រគល់វត្ថុអនុស្សាវរីយ៍ និងអំណោយមនុស្សធម៌ជូនរដ្ឋបាលខេត្តស្វាយរៀង*

# ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកចង្ក្រានសន្សំសំចៃថាមពល ចែកជូនប្រជាពលរដ្ឋនៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង




*លោកជំទាវ មាន សំអាន អញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅឃុំក្រាំងលាវ*

ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុមនិងជាអនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជានិងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានអញ្ជើញចុះសួរសុខទុក្ខនិងនាំយកចង្ក្រានសន្សំសំចៃថាមពលចែកជូនប្រជាពលរដ្ឋចំនួន៤០០គ្រួសារ និងសម្លៀកបំពាក់ចែកជូនប្រជាការពារភូមិចំនួន១១៣កំប្លេ នៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃសៅរ៍ ទី១១ ខែមេសា ឆ្នាំ២០២៦។

មានប្រសាសន៍ក្នុងពេលនោះ **លោកជំទាវប្រធាន** បាននាំបណ្តាំសួរសុខទុក្ខពីសំណាក់ សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** និងថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រកបដោយក្តីនឹករលឹកជូនដល់ប្រជាពលរដ្ឋនៅទូទាំងខេត្តកំពង់ឆ្នាំង។

ជាមួយគ្នានោះ **លោកជំទាវប្រធាន** បានលើកឡើងពីសភាពការណ៍ព្រំដែន ហើយថ្លែងអំណរគុណ និងដឹងគុណយ៉ាងធំធេងចំពោះកងកម្លាំងគ្រប់ប្រភេទដែលឈរជើងនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដោយបានលះបង់កម្លាំងកាយចិត្ត ដើម្បីការពារអធិបតេយ្យនិងបូរណភាពទឹកដីជាតិ។ លោកជំទាវបានគូសបញ្ជាក់ថា ចាប់តាំងពីពេលចូលជាធរមាននៃបទឈប់បាញ់ រាជរដ្ឋាភិបាលនិងកងកម្លាំងកម្ពុជា តែងតែប្រកាន់យ៉ាងម៉ឺងម៉ាត់ ច្បាស់លាស់ ក្នុងការគោរពនិងអនុវត្តយ៉ាងពេញលេញខ្ជាប់ខ្ជួន ប្រកបដោយការទទួលខុសត្រូវខ្ពស់លើសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ




*លោកជំទាវ មាន សំអាន មានប្រសាសន៍សំណេះសំណាលជាមួយប្រជាពលរដ្ឋ*

(GBC) ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥, សេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចព្រមព្រៀងសន្តិភាពរវាងកម្ពុជា-ថៃ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី និងកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀត ដើម្បីឆ្ពោះទៅការធ្វើឱ្យប្រសើរឡើងវិញឆាប់រហ័សនិងការវិលត្រឡប់ទៅរកប្រក្រតីភាព សន្តិភាព ស្ថិរភាពយូរអង្វែង។ ម្យ៉ាងទៀត ក្នុងឱកាសដែលប្រជាពលរដ្ឋទូទាំងប្រទេសកំពុងជួបជុំក្រុមគ្រួសារសប្បាយរីករាយអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ បងប្អូនកងទ័ពនៅតែបន្តឈរជើងការពារជាតិនិងអធិបតេយ្យយ៉ាងស្វាហាប់ បង្ហាញពីគំរូវីរភាពដ៏ថ្លៃថ្លាដែលបានមកពីការលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីប្រជាជនយើង។ ចំពោះស្ថានការណ៍នៃសង្គ្រាមមជ្ឈិមបូព៌ាដែលនាំឱ្យមានវិបត្តិថាមពលប្រេងឥន្ធនៈសកលបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរលើការនាំចូលនិងការបញ្ជាទិញប្រេងនិងឧស្ម័នឥន្ធនៈមកកម្ពុជា លោកជំទាវបានអំពាវនាវឱ្យប្រជាពលរដ្ឋចូលរួមអនុវត្តវិធានការសន្សំសំចៃក្នុងការប្រើប្រាស់ថាមពលអគ្គិសនី ប្រេងឥន្ធនៈ ដើម្បីកាត់បន្ថយការចំណាយថវិកា ដែលជាវិធានការទប់ទល់នឹងផលប៉ះពាល់នៃវិបត្តិកើតមាននេះសម្រាប់រយៈពេលយូរ។

**លោកជំទាវប្រធាន** បានថ្លែងអំណរគុណនិងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទាំងអស់ បន្តពង្រឹងសាមគ្គីភាពឯកភាពគ្នាជាធ្លុងមួយនិងជឿជាក់លើរាជរដ្ឋាភិបាលដែលមាន សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដឹកនាំចាត់ចែងការងារគ្រប់យ៉ាង ដើម្បីការពារសុខសន្តិភាព ស្ថិរភាព និងអធិបតេយ្យជាតិ ឱ្យបានគង់វង្សដោយសន្តិវិធីក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិនិងស្មារតីពហុភាគីនិយម ជាកម្លាំងចលករដ៏ខ្លាំងក្លាដែលគ្មានអ្នកណាមកបំបែក និងមកជាន់ពន្លិចបានឡើយ។

អំណោយដែលបានផ្តល់ជូនក្នុងឱកាសនោះ គឺបានមកពីការឧបត្ថម្ភរបស់ក្រុមហ៊ុន SIPCO ដោយប្រជាពលរដ្ឋក្នុង១គ្រួសារ ទទួលបានចង្ក្រានសន្សំសំចៃថាមពលចំនួន១ និងការឧបត្ថម្ភរបស់ឯកឧត្តម **ជួប រតនា** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងលោកជំទាវ រួមមានសម្លៀកបំពាក់ប្រជាការពារភូមិចំនួន១១៣កំប្លេ ព្រមទាំងឧបត្ថម្ភជូនដល់សាលាឃុំក្រាំងលាវ ទឹកប្រាក់ចំនួន១លានរៀលផងដែរ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន









*ទិដ្ឋភាពក្រុមសមាជិកាព្រឹទ្ធសភា ចែកចង្ក្រានសន្សំសំចៃថាមពល ជូនប្រជាពលរដ្ឋនៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ចំនួន២លើក៖**



នាថ្ងៃទី២៦ ខែមីនា និងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើរបាយការណ៍លទ្ធផលការងារប្រចាំខែមីនា របាយការណ៍ចុះបេសកកម្មចន្លោះសម័យប្រជុំ និងបញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ចំនួន១លើក**



នារសៀលថ្ងៃពុធ ទី១ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្តា** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានិងសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

**❈កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន១លើក**

នាព្រឹកថ្ងៃចន្ទ ទី២០ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយតំណាងធនាគារជាតិនៃកម្ពុជាស្តីពី «នីតិវិធីអភិបាលបណ្តោះអាសន្ននិងការជម្រះបញ្ជីនៃ



ធនាគារ» នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ចំនួន១លើក**

នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានិងសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្ម



ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន១លើក**



នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីសាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើការងារបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែមីនា ប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ និងទិសដៅបន្ត របាយការណ៍ស្តីពីជំនួបពិភាក្សាការងារជាមួយក្រសួងព័ត៌មាន ការងារចន្លោះសម័យប្រជុំលើកទី៤និងទី៥ព្រឹទ្ធសភានីតិកាលទី៥និងបញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ចំនួន១លើក**



នារសៀលថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីសាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានិងបញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៦ព្រឹទ្ធសភា ចំនួន៣លើក៖**

លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំជាមួយគណៈកម្មការទី៤ព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នៅសាលភក្តីវិក្រមព វិមានព្រឹទ្ធសភា នារសៀលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦។



-កិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានិងបញ្ហាផ្សេងៗ នារសៀលថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦។



-កិច្ចប្រជុំពិនិត្យរបាយការណ៍លើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានិងបញ្ហាផ្សេងៗ នៅសាលភក្តីវិក្រមព វិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦។

**❈កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន១លើក**

នាព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤



ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសហការី ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នៅសាលភក្តីវិក្រម៣ វិមានព្រឹទ្ធសភា។

### ❈កិច្ចប្រជុំគណៈកម្មការពិសេស ចំនួន១លើក



នាព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំជាមួយគណៈកម្មការពិសេស ប្រធានគណៈ-កម្មការនានា ក្រុមសមាជិកា ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅសាលភក្តីវិក្រម៣ វិមានព្រឹទ្ធសភា។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន២លើក៖

ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំជាមួយមន្ត្រីការិយាល័យជំនួយការ ដើម្បីណែនាំពីការបែងចែកសម្ភារៈនិងគ្រឿងឧបភោគ បរិភោគជូនអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦។





-កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើរបាយការណ៍លទ្ធផលការងារប្រចាំខែមេសានិងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៦ ផែនការប្រតិបត្តិរបស់គណៈកម្មការប្រចាំឆ្នាំ២០២៧និង២០២៨និងបញ្ហាផ្សេងៗ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន១លើក



នាព្រឹកថ្ងៃអង្គារ ទី៣១ ខែមីនា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើការបូកសរុបលទ្ធផលការងារប្រចាំខែមីនា ត្រីមាសទី១ និងទិសដៅការងារបន្ត ឆ្នាំ២០២៦ និងនៅចន្លោះ

សម័យប្រជុំលើកទី៤ និងលើកទី៥ ព្រឹទ្ធសភានីតិកាលទី៥ ព្រមទាំងការទូទាត់ចំណូល ចំណាយថវិការបស់គណៈកម្មការប្រចាំត្រីមាសទី១ ឆ្នាំ២០២៦និងបញ្ហាផ្សេងៗ។

**❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៤) ចំនួន១លើក**



នារសៀលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សានិងត្រៀមយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា សេចក្ដីស្នើច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានិងបញ្ហាផ្សេងៗ។

**❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ចំនួន១លើក**



នាថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សា និងត្រៀមឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានិងសេចក្ដីស្នើច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

**❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក**

នាព្រឹកថ្ងៃអង្គារ ទី២១ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យសម្រេចលើសេចក្ដីព្រាងរបាយការណ៍ស្ដីពី សកម្មភាពលទ្ធផលការងារប្រចាំខែមេសានិងលើកទិសដៅការងារបន្ត។

**❋គណៈកម្មការទី១០ព្រឹទ្ធសភា ជួបភ្ញៀវជាតិ ចំនួន១លើក**



នាថ្ងៃព្រហស្បតិ៍ ទី២៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមហ៊ុន E-School Cambodia និងវិទ្យាស្ថានបញ្ញាឌីជីថលកម្ពុជា នៅសាលភក្ដីវិក្រម៣ វិមានព្រឹទ្ធសភា។

**❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចំនួន២លើក៖**

ឯកឧត្តម **ឈួន ឆាម** ប្រធានស្ដីទីក្រុម បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម



-កិច្ចប្រជុំពិនិត្យពិភាក្សាលើរបាយការណ៍លទ្ធផលនៃ

ការរៀបចំពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៃស្រុកបូរីជលសារនិងក្រុងដូនកែវ ខេត្តតាកែវ ព្រមទាំងទូទាត់ចំណូលចំណាយថវិកាប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥និងបញ្ហាផ្សេងៗ នារសៀលថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៦។

-កិច្ចប្រជុំពិនិត្យពិភាក្សាលើរបាយការណ៍សកម្មភាពប្រចាំខែមេសានិងទិសដៅខែឧសភា ឆ្នាំ២០២៦ ផែនការសកម្មភាពចន្លោះសម័យប្រជុំលើកទី៥និងទី៦ និងបញ្ហាផ្សេងៗ នាព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦។



## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស



❈ចាប់ពីថ្ងៃ១៣ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឌី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងមហាសន្និបាតលើកទី១៥២ នៃសហភាពអន្តរសភា (IPU-152) និងកិច្ចប្រជុំពាក់ព័ន្ធ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងអ៊ីស្តង់ប៊ុល ប្រទេសតួកគីយ៉េ។



❈ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកិច្ចការសភា នៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងព័រល្វី កោះម៉ូរីស។

❈ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមព្រឹត្តិការណ៍ «អ្វីៗដើម្បីលទ្ធិប្រជាធិបតេយ្យ (All About Democracy)» នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

❈នារសៀលថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៦ សម្តេចរាជបុត្រី ព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងអមដង្ហែព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងជំនួបព្រះរាជសវនាការជាមួយឯកឧត្តម **កៃ ឌី** (Cai Qi) សមាជិកគណៈអចិន្ត្រៃយ៍នៃការិយាល័យនយោបាយ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន នៅវិមានរដ្ឋដាយយូតៃ រដ្ឋធានីប៉េកាំង។

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖



-ដឹកនាំក្រុមការងារបច្ចេកទេសសំណង់និងកសិកម្ម ដើម្បីពិនិត្យតាមដានផ្នែកបច្ចេកទេសនិងជំរុញការងារសាងសង់រោងចក្រផលិតជីធម្មជាតិ ដែលមានកម្លាំងផលិត១០០តោនក្នុងមួយថ្ងៃ នៅភូមិដូនអាត់ ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលជាមួយសិស្សានុសិស្សមកពីសាលា Paragon International School មកស្នាក់នៅលេងកម្សាន្ត នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឬទ្ធី សែនជ័យ ព្រមទាំងបានរៀបចំអាហារនិងជូនក្រុមសិស្សានុ-សិស្សជិះឡូរីទស្សនាកម្សាន្ត នៅភូមិស្វាយជង្គំ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៦។



-ទទួលជួបពិភាក្សាការងារជាមួយសហគមន៍ដាំត្រសក់ផ្អែម នៅស្រុករតនមណ្ឌល ស្រុកកំរៀង ស្រុកភ្នំព្រឹក ស្រុកបវេល ខេត្តបាត់ដំបង, ខេត្តប៉ៃលិន (ភ្នំស្ពង) និងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដើម្បីដាំត្រសក់ផ្អែមក្នុងបរិមាណ៣០០ ទៅ៤០០តោន/ឆ្នាំ ក្នុងផ្ទះសំណាញ់ចំនួន១៨៥ខ្នង នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឬទ្ធី សែនជ័យ ស្ថិតក្នុងភូមិសំរោងជើងភ្នំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៦។

-ទទួលជួបប្រជាពលរដ្ឋនាំយកត្រីកម្រចំនួន៥ក្បាល រួមមានត្រីអាម៉ាហ្សូនចំនួន៣ក្បាលដែលមានទម្ងន់ប្រមាណជា៣០០គីឡូក្រាម និងត្រីក្រពើចំនួន២ក្បាលដែលមានទម្ងន់ប្រមាណជា៥០គីឡូក្រាម ទៅលែងចូលស្រះអភិរក្សទី២ ព្រមទាំងជួបសំណេះសំណាលសួរសុខទុក្ខកម្មករ និងចុះពិនិត្យមើលសកម្មភាពកម្មករថែទាំចម្ការដូងក្រអូបចំនួន១២.២០០ដើម នៅភូមិស្វាយជង្គំ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៦។

-នាំយកទេយ្យវត្ថុ និងបច្ច័យប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សា ដើម្បីឧទ្ទិសជូនដល់ដួងវិញ្ញាណក្ខន្ធជូនដល់ឧបាសក **ភា ម៉ុង** និងឧបាសិកា **គីម អិន** ត្រូវជាឪពុកម្តាយឯកឧត្តមបណ្ឌិត ដែលបានចែកឋាន ព្រមទាំងនាំយកអំណោយចែកជូនកុមារានិងកុមារី នៅវត្តមហានាមស្វាយមេ និងភូមិត្រពាំងទ្រា ឃុំរៀង ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៦។

-ចុះពិនិត្យមើលកសិដ្ឋានចិញ្ចឹមជ្រូក កសិដ្ឋានចិញ្ចឹមត្រី រោងចក្រអគ្គិសនីដើរដោយថាមពលលាមកជ្រូកកម្លាំង១.៥០០គីឡូវ៉ាត់ ព្រមទាំងមើលកាកសំណល់ស្នែងដូងប្រេង និងលាមកជ្រូកប្រមាណជា១ម៉ឺនតោន អាចយកមកផលិតជាជីធម្មជាតិបានយ៉ាងមានប្រសិទ្ធភាពល្អបំផុត នៅចុងខាងលិចជួរភ្នំបូកគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦។

-និមន្តព្រះសង្ឃចំនួន៥អង្គ សូត្រមន្តសិរីសួស្តីថ្ងៃចូលឆ្នាំ ព្រមទាំងរៀបចំជប់លៀង ជូនបុគ្គលិក កម្មករ និងប្រជាជន



ដើមភាគតិច ដើម្បីចូលរួមអបអរសាទរក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នៅភូមិកែវផុស ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦។

-ចុះពិនិត្យសកម្មភាពនិងជំរុញការងារសាងសង់រោងចក្រផលិតជីធម្មជាតិឱ្យបានរួចរាល់និងចាប់ដំណើរការតាមការគ្រោងទុក នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ភូមិសំរោងជើងភ្នំ ឃុំសែនដី ស្រុកសំរោង-ទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋអញ្ជើញមកពីឃុំស្រម៉ ខេត្តកំពង់ឆ្នាំង មកទស្សនាលេងកម្សាន្តនៅក្នុងតំបន់អភិវឌ្ឍន៍រមណីយដ្ឋានកសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងជួបសំណេះសំណាលសួរសុខទុក្ខកម្មករ និងចុះពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធនានា សួនសត្វ និងទំនប់ទឹក នៅភូមិដូនអាត់ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៦។



-រៀបចំនាំយកចង្ហាន់និងបច្ច័យប្រគេនព្រះសង្ឃ ព្រមទាំងមានការរៀបចំលេងល្បែងប្រជាប្រិយខ្មែរជូនកម្មករនិងប្រជាពលរដ្ឋ ក្នុងតំបន់រមណីដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ស្ថិតក្នុងវត្តបឹងខ្នា ភូមិសំរោងជើងភ្នំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦។

-ចុះពិនិត្យកសិដ្ឋានចិញ្ចឹមមាន់មេយកពងចំនួន៣ម៉ឺនមេ និងពង្រឹងពង្រីកការចិញ្ចឹម ដើម្បីបំពេញតម្រូវការទីផ្សារតទៅអនាគតនិងអាចបិទបញ្ចប់ការនាំចូលមកពីបរទេស នៅភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ព្រមទាំងចុះសួរសុខទុក្ខនិងនាំយកអំណោយចែកជូនប្រជាពលរដ្ឋដែលកំពុងបំពេញការងារតាមភូមិចម្ការកៅស៊ូនានា ដែលពួកគាត់មិនបានទៅលេងស្រុកកំណើត ក្នុងរដូវបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នៅភូមិឫទ្ធី៤ ឃុំកែវផុស ស្រុកស្ទឹងហាវ និងភូមិឫទ្ធី៥ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៦។



-ទទួលអាហារពេលព្រឹកនិងចែកថវិកាមួយចំនួនដល់កុមារា និងកុមារីក្មេងសឹកចំនួន៤៧នាក់ មកពីភូមិព្រៃចាន់ និងភូមិជោគជ័យ នៃខេត្តបន្ទាយមានជ័យ នៅអាហារដ្ឋានកាហ្វេដូងប្រេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦។

-ចុះពិនិត្យមើលទំនប់ប្រឡាយនិងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត ដែលឯកឧត្តមបណ្ឌិតបានសាងសង់កាលពីឆ្នាំ១៩៩៥-១៩៩៦ នៅប្រាសាទភ្នំជីសូរ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលសួរសុខទុក្ខនិងនាំយកកង់អាគុយថ្មី១គ្រឿងជូនប្តីប្រពន្ធមកពីភូមិដើមពោធិ៍ ឃុំរមេញ ស្រុក

កោះអណ្តែត ខេត្តតាកែវ ព្រមទាំងបានផ្តល់ការងារជូនពួកគាត់ នៅភូមិដើមពោធិ៍ ឃុំរមេញ ស្រុកកោះអណ្តែត ខេត្តតាកែវ នារសៀលថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦។

❈នាថ្ងៃសុក្រ ទី២៤ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភានិង ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ ជាមួយក្រុមប្រឹក្សាឃុំស្រែអំបិល ឃុំបឹងព្រាវ ឃុំជ្រោយស្វាយ និងក្រុមប្រឹក្សាស្រុកស្រែអំបិល នៅសាលាស្រុកស្រែអំបិល ខេត្តកោះកុង។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូនិងពិនិត្យទីតាំងអគារសិក្សា១កន្លែង នៅសាលាបឋមសិក្សាអំពិលក្រៅ ដែលមានសភាពចាស់ទ្រុឌទ្រោមខ្លាំង ដើម្បីត្រៀមរៀបចំសាងសង់ថ្មី ព្រមទាំងចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិអំពិលក្រៅ ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នារសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦។



-ដឹកនាំគណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា ចុះសួរសុខទុក្ខនិងនាំយកអំណោយប្រគល់ជូនវីរកងទ័ពជួរមុខដែលប្រចាំការនៅតំបន់មុំបី នៅខេត្តព្រះវិហារ នាថ្ងៃទី៧ ដល់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦។

-ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចូលរួមដាក់ឱ្យដំណើរការជាផ្លូវការរោងចក្រប្រព្រឹត្តកម្មទឹកស្អាត អណ្តូងតាសី និងបើកការដ្ឋានសាងសង់គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតបន្ថែមសម្រាប់ខេត្តចំនួន៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិអណ្តូងតាសី សង្កាត់ព្រៃធ្លាក់ ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦។

❈ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីសម្ពោធអគារសាលាមត្តេយ្យ ចំនួន១ខ្នង មាន៤បន្ទប់និងសមិទ្ធផលនានា ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ នៅសាលាបឋមសិក្សាពោធិ៍អណ្តែត ស្ថិតក្នុងឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦។

-ចូលរួមពិធីបួងសួងសុំសេចក្តីសុខក្នុងព្រឹត្តិការណ៍សង្ក្រាន្តព្រៃវែង ឆ្នាំ២០២៦ នៅទួលបារាយណ៍អណ្តែតភូមិលេខ១ សង្កាត់កំពង់លាវ ខេត្តព្រៃវែង និងចូលរួមពិធីសម្ពោធផ្ទាំងគំនូរចំនួន៤ផ្ទាំង អំពីសង្គ្រាមថៃឈ្លានពានកម្ពុជា នៅជញ្ជាំងអគាររោងទូកង (កម្ពោជិកបុត្តាខេមរាតរី) មុខសាលាខេត្តព្រៃវែង ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦។

-ចូលរួមពិធីសូត្រមន្តពូនភ្នំខ្សាច់ ស្រង់ព្រះ រាប់បាត្រ វត្តសំសមី ស្ថិតក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងលោកជំទាវ នាព្រឹកថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦។



❈នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឈួន ឆាម** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចូលរួមរំលែកមរណទុក្ខនិងគោរពវិញ្ញាណក្ខន្ធសព លោក **រស់ ម៉ុនធឿន** អភិបាលនៃគណៈអភិបាលស្រុកអង្គរបូរី ខេត្តតាកែវ នៅភូមិអង្គក្រូច ឃុំបូរីជលសារ ស្រុកបូរីជលសារ ខេត្តតាកែវ។



❈នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តមសន្តិបណ្ឌិត **តេង សាវង្ស** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបួងសួងសុំសេចក្តីសុខ នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅប្រាសាទបាណន់ ភូមិបាណន់ ឃុំកន្ទឺ២ ស្រុកបាណន់ ខេត្តបាត់ដំបង ។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារខែមីនានិងទិសដៅការងារខែមេសា ឆ្នាំ២០២៦ ព្រមទាំងបន្តយុទ្ធនាការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ (Online Scams) ពង្រឹងការការពារសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ និងបានឧបត្ថម្ភអង្ករ ថវិកាមួយចំនួនជួយថែទាំសុខភាពមនុស្សចាស់ប្រចាំខែផងដែរ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីជូនពរអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ គ្រិស្តសករាជ២០២៦ ក្រោមអធិបតីភាពសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះ-មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិបាក់រនាស់ សង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦។

-ចូលរួមពិធីក្រុងពាលីសុំសេចក្តីសុខចម្រើន ក្នុងការរៀបចំព្រឹត្តិការណ៍សង្ក្រាន្តស្វាយរៀង ក្រោមអធិបតីភាពសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅបរិវេណរង្វង់មូលវិមានឯករាជ្យ ក្រុងស្វាយរៀង ខេត្តស្វាយរៀង នារសៀលថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖

-អមដំណើរសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមក្នុងពិធីប្រគល់-ទទួលផ្ទះ និងដីឡូត៍លំនៅឋានសម្បទានសង្គមកិច្ចជូនគ្រួសារអតីតយុទ្ធមិត្តឆ្នាំ១៩៧៨ ចំនួន១២៦ផ្ទះនិងចែកអំណោយជូនប្រជាពលរដ្ឋដែលជា



ម្ចាស់ផ្ទះទាំង១២៦ផ្ទះ នៅភូមិធ្លកថ្មី ឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦។

-ចូលរួមសូត្រមន្ត ទទួលអំណរសាទរទេវតាឆ្នាំថ្មី ឆ្នាំមមី ក្រោមអធិបតីភាពសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តព្រៃធ្លាក់ សង្កាត់ព្រៃធ្លាក់ ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៦។



❈នារសៀលថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភានិង ឯកឧត្តម **អ៊ុន វណ្ណា** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យផ្ការស្មីសាមគ្គី ដើម្បីប្រមូលបច្ច័យយកមកសាងសង់ប្រាសាទសិរីជ័យ បឹងតាកែវ នៅសាលាខេត្តតាកែវ។

❈ឯកឧត្តម **លេខ ទី** លេខាធិការគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញ៖

-នាំយកទេយ្យវត្ថុនិងបច្ច័យប្រគេនព្រះសង្ឃគង់នៅវត្តរតនរង្សី សម្រាប់ត្រៀមរៀបចំពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅភូមិល្វេ ឃុំល្វេ ស្រុកកោះសូទិន ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៦។

-ជួបសួរសុខទុក្ខលោក **ប៊ុន សុខហ៊ាង** អតីតមន្ត្រីស្នងការដ្ឋាននគរបាលខេត្តសៀមរាប កំពុងសម្រាកព្យាបាលជំងឺ នារសៀលថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦។



❈នាថ្ងៃសុក្រ ទី១៥ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **លេខ ទី** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភានិង ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខនិងជូនថវិកាមួយចំនួនដល់លោក **ប៊ុន សុខ** អតីតមន្ត្រីស្នងការដ្ឋាននគរបាលខេត្តសៀមរាបដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន នៅខេត្តសៀមរាប។

❈ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ នាយប៉ុស្តិ៍នគរបាល ស្មៀន និងលោកមេភូមិ នៃសង្កាត់ព្រែកប្រា ដើម្បីជួបប្រាស្រ័យ ពិគ្រោះយោបល់ ស្វែងយល់ពីការអភិវឌ្ឍ ព្រមទាំងតម្រូវការ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំសង្កាត់ នៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦។

-ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនបងប្អូនសាសនិកអិស្លាម នៅភូមិអង្គជា ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦។



❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈ-កម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមពិធីសំណេះសំណាលនិងចែកគ្រឿងឧបភោគបរិភោគ ជូនលោកយាយ លោកតា ដែលមានវ័យ៧០ឆ្នាំឡើង អតីតនិវត្តជន ជនមានពិការភាព និងប្រជាពលរដ្ឋភៀសសឹក ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅមណ្ឌលភៀសសឹក ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦។



-ចូលរួមពិធីសំណេះសំណាលនិងចែកអំណោយជូនប្រជាពលរដ្ឋសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-ជប៉ុន មន្ទីរពេទ្យបង្អែកស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក និងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នារសៀលថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦។




-ចូលរួមពិធីសំណេះសំណាលនិវត្តជនជាអតីតមន្ត្រីរាជការ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារ សាខាពន្ធដារ សាខាគយ និងរដ្ឋាករខេត្ត នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។



-ចូលរួមពិធីសំណេះសំណាលនិងចែកគ្រឿងឧបភោគបរិភោគ និងបានឧបត្ថម្ភថវិកាមួយចំនួនជូនវីរកងទ័ពជួរមុខ នៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នៅភូមិភ្នំកន្ទួត សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦។




-ចូលរួមពិធីសំណេះសំណាលនិងចែកអំណោយជូនប្រជាពលរដ្ឋចំនួន១៥គ្រួសារ នៅសាលាឃុំសារង្គ ស្រុក

ស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៦។

❈លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាធិបតីក្នុងពិធីសំណេះសំណាលនិងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សាថ្មី១ខ្នង មាន៦បន្ទប់ កម្ពស់២ជាន់ និងសមិទ្ធផលនានា នៃសាលាបឋមសិក្សាវល្លិ៍យាវ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦។

-ចុះសួរសុខទុក្ខលោក **ស៊ាន់ គឹមសើ** គ្រូបង្រៀន នៅសាលាបឋមសិក្សាអូរសោលា ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យកាល់ម៉ែត នារសៀលថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦។

-ជាអធិបតីក្នុងពិធីជួបសំណេះសំណាលនិងជូនវត្ថុ



អនុស្សាវរីយ៍ជូនអតីតមន្ត្រីចូលនិវត្តន៍មកពីអង្គភាពសាលាខេត្ត មន្ទីរកិច្ចការនារី និងមន្ទីរសោព័ត៌មាន នៅសាលាខេត្តកំពង់ធំ នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦។

-ចូលរួមក្នុងពិធីបើកព្រឹត្តិការណ៍សង្ក្រាន្តខេត្តកំពង់ធំនិងពិធីអបអរសាទរទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ លើកទី៩ ឆ្នាំ២០២៦ ក្រោមអធិបតីភាពឯកឧត្តម



**វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសួនស្ទឹងសែន ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាល្ងាចថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។



-ចូលរួមពិធីបុណ្យទក្ខិណានុប្បទាន បង្សុកូល និងរាប់បាត្រព្រះសង្ឃចំនួន១៥៩អង្គ ជាមួយរដ្ឋបាលខេត្តកំពង់ធំ ដើម្បីឧទ្ទិសមហាកុសលផលបុណ្យជូនដល់ដួងវិញ្ញាណក្ខន្ធវីរកងទ័ពដែលបានពលីជីវិតក្នុងសមរភូមិ នៅសួនស្ទឹងសែន ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៦។



-នាំយកទេយ្យទាន គ្រឿងឧបភោគ បរិភោគ ចង្ហាន់ និងបច្ច័យមួយចំនួនទៅប្រគេនព្រះគ្រូចៅអធិការវត្តឥន្ទ្រសំវរៈ(ហៅវត្តកំពង់ធំ) វត្តទេពនិម្មិត(ហៅវត្តធម្មយុត្ត) វត្តសែនសិរី(ហៅវត្តក្តីសែន) នៅក្រុងស្ទឹងសែន និងវត្តព្រះពុទ្ធជិនរាជ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦។



-ជាអធិបតីក្នុងពិធីកាត់ខ្សែបូឆ្លងកុដិនិងសមិទ្ធផលនានា ក្នុងវត្តបិយម្ពនៃ(ហៅវត្តថ្មី) ស្ថិតក្នុងភូមិសង្គម ឃុំដំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៦។

❈នាព្រឹកថ្ងៃពុធ ទី១៥ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញនាំយកទេយ្យទាននិងថ្វាយផ្កាចំពោះព្រះអង្គខ្មៅ នៅវត្តព្រៃអង្គក្នុង ឃុំជូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលថ្នាក់ដឹកនាំនិងប្រជាពលរដ្ឋនិង ចូលរួមរំលែកមរណទុក្ខ គោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ឃុំជុំក្រៀល និងនៅភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២៧ ថ្ងៃទី២៩ និងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦។



-ចុះពិនិត្យមើលវឌ្ឍនភាពនៃការសាងសង់ព្រះវិហារនិង ទីតាំងសាងសង់សាលារៀនសម្រាប់បម្រើដល់ផលប្រយោជន៍ របស់ប្រជាពលរដ្ឋ សុខទុក្ខប្រជាពលរដ្ឋនៅភូមិដូង ឃុំស្ទឹងកែវ និងចូលរួមរំលែកមរណទុក្ខ គោរពវិញ្ញាណក្ខន្ធសពប្រជាពល-រដ្ឋ នៅភូមិកំពង់ក្រេង ឃុំកំពង់ក្រែង ស្រុកទឹកឈូ និងនៅ ភូមិស្រែ សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នាថ្ងៃទី៧ ថ្ងៃទី១៣ និងថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦។



-ជួបសំណេះសំណាលបងប្អូនប្រជាពលរដ្ឋ នៅភូមិ ត្រពាំងសង្កែ (ក្បាលរមាស) ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦។



-ចូលរួមពិធីសំណេះសំណាលនិស្សិតជ័យលាភីអាហា-រូបករណ៍របស់ឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** នៅសាល សន្និសីទបូកគោ ខេត្តកំពត ក្រោមអធិបតីភាពឯកឧត្តម បណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នាព្រឹកទី១២ ខែមេសា ឆ្នាំ២០២៦។



❋នារសៀលថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **កង សៅរ៍ធន** សមាជិកាគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យគម្រប់៧ថ្ងៃ លោក **អ៊ុន ខេត** ជំទប់ទី១ឃុំបឹងសាលាខាងត្បូង នៅភូមិស្វាយផ្អែម ឃុំបឹង-សាលាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត។

❋ឯកឧត្តម **គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលនិងស្តាប់នូវបញ្ហាប្រឈមរបស់បងប្អូនប្រជាពលរដ្ឋ នៅភូមិមុខខេត្ត សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងស្តាប់នូវបញ្ហាប្រឈមរបស់បងប្អូនប្រជាពលរដ្ឋ នៅឃុំព្រៃស្នៀត ស្រុកពារាំង ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៦។

❋លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈ-កម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាអធិបតីក្នុងពិធីបុណ្យឆ្លងសមិទ្ធផលនានា ក្នុងវត្តសុវណ្ណគិរីប្រសិទ្ធារាមភ្នំដំរីរមៀល ស្ថិតក្នុងស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦។

-ប្រគេនទេយ្យវត្ថុនិងបច្ច័យកសាងដល់វត្តចំនួន៧ និងរាប់បាត្រ នៅភូមិជ្រៃយោង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៦។



-បង្សុកូល ប្រគេនទេយ្យទាន និងបច្ច័យដល់ព្រះសង្ឃចំនួន៥អង្គ នៅភូមិក្នុងគេហដ្ឋាន ស្ថិតក្នុងភូមិជើងធ្នុក ស្រុកបាធាយ ខេត្តកំពង់ចាម នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៦។

❋ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលនិងជូនពរដល់ក្រុមប្រឹក្សាឃុំចំនួន៣៤នាក់ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។

-នាំយកថវិកាមួយចំនួនជូនដល់សាខាកាកបាទក្រហម



ខេត្តសៀមរាប នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦។

❋ឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមប្រារព្ធទិវាអន្តរជាតិរំលឹកដល់ជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកលើកទី២០និងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សួនសុវត្ថិភាពចរាចរណ៍ផ្លូវគោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅវិទ្យាល័យក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៦។

-ចូលរួមពិធីបុណ្យផ្កាប្រាក់មហាសាមគ្គី នៅវត្តសុវណ្ណគិរី ភូមិព្រៃគ្រីត្បូង ឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នារសៀលថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៦។



-ចូលរួមក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្តនិងពុទ្ធាភិសេកព្រះអង្គ នាឱកាសពិធីបុណ្យពុទ្ធាភិសេក និងសម្ពោធឆ្លងសាលាបុណ្យភូមិស្នាកណ្ដាល ព្រមទាំងសមិទ្ធផលនានា នៅភូមិស្នាកណ្ដាល ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៦។



-ជាអធិបតីក្នុងពិធីសម្ពោធឆ្លងសាលាបុណ្យភូមិស្នាកណ្ដាលនិងសមិទ្ធផលនានា ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនគណៈកម្មការគ្រប់គ្រងសាលាបុណ្យនិងចែកជូននូវក្រមាចំនួន១ ក្រណាត់ស១ដុំ និងថវិកាមួយចំនួនដល់ពុទ្ធបរិស័ទ លោកតា លោកយាយ ប្រជាពលរដ្ឋ កម្លាំងការពារ នៅភូមិស្នាកណ្ដាល ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦។

❈លោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីចម្រើនព្រះបរិត្តប្រសិទ្ធពរជ័យ សិរីមង្គលជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ នៅរាជធានីភ្នំពេញ នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមបុណ្យផ្កាមហាសាមគ្គី ក្រោមអធិបតីភាពសម្តេចមហាមន្ត្រី **គុយ សុផល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ដើម្បីប្រមូលបច្ច័យយកទៅជួសជុលព្រះវិហារវត្តសុវណ្ណគីរី នៅភូមិព្រៃគ្រីត្បូង ឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៦។



-ចូលរួមពិធីសូត្រមន្តអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ជាមួយរដ្ឋបាលខេត្ត នៅសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។



-ចូលរួមពិធីសូត្រមន្តចម្រើនព្រះបរិត្ត អបអរសាទរក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ នៅសាលាស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៦។

-ចូលរួមពិធីបើកសង្ក្រាន្តឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ២០២៦ នៅបរិវេណសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៦។

❈នាថ្ងៃទី៥ ខែមេសា ឆ្នាំ ២០២៦ ឯកឧត្តម **អ៊ុន ខណ្ណា** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាការពារនិងក្រុមការងារឃុំព្រៃផ្ដៅ នៅស្រុកព្រៃកប្បាស ខេត្តតាកែវ។

❈នាថ្ងៃទី៤ ថ្ងៃទី៥ ថ្ងៃទី១១ និងថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខជាមួយសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋ នៅខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង និងខេត្តសៀមរាប។

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❈នារសៀលថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៦ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៨រូប បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបើក «ព្រឹត្តិការណ៍បុណ្យទន្លេលើកទី១០ ឆ្នាំ២០២៦» ក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រីនិងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្រុងក្រចេះ ខេត្តក្រចេះ។



❈នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៦ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៦រូប បានអញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានគម្រោងគ្រប់គ្រងធនធានទឹកចម្រុះហ្វូណនតេជោ កំណាត់ទី២ប្រវែង១៥៧,៨គីឡូម៉ែត្រ (ព្រែកពោធិ៍ ខេត្តកណ្ដាល-សមុទ្រ ខេត្តកែប) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅភូមិត្រោយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។

❈នាព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់ផ្សារទំនើប ជីប ម៉ុង 6A។

❈នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមុខងារសាធារណៈនិងពិសាអាហារសាមគ្គីថ្ងៃត្រង់ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នៅដីព្រៃមៀសែនជ័រ សែនសុខ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។




❈នាថ្ងៃសៅរ៍ ទី៤ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលអំណោយមនុស្សធម៌លើកទី១៨ របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ នៅវិមានព្រឹទ្ធសភា។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈ-កម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីបិទកិច្ចប្រជុំស្ដីពី «អភិបាលកិច្ចនិងការ

គ្រប់គ្រង» ជូនសាខាកាកបាទក្រហមកម្ពុជា ទាំង២៥រាជធានី ខេត្ត ក្រោមអធិបតីភាពលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហម



កម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦។



-ជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចូលក្រាបថ្វាយបង្គំនិងនាំយកទេយ្យវត្ថុរួមទាំងបច្ច័យមួយចំនួនធំដែលជាសទ្ធាជ្រះថ្លារបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិតនិងសម្តេចតេជោ **ហ៊ុន សែន** ថ្វាយចំពោះ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **នន្ទ ង៉ែត** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា និងជាសម្តេចព្រះចៅអធិការវត្តបទុមវតីរាជវរារាម ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សារបស់សម្តេចជាអម្ចាស់ គម្រប់ ១០២ យាងចូល១០៣ព្រះវស្សា នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៦។



❋នាព្រឹកថ្ងៃពុធ ទី៨ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមទិវាព្រះពុទ្ធសាសនាអន្តរជាតិឆ្នាំ២០២៦ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ។

❋នាថ្ងៃព្រហស្បតិ៍ ទី២៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ញ៉ែម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកទិវាជាតិវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍លើកទី៤ ឆ្នាំ២០២៦ ក្រោមអធិបតី-ភាពឯកឧត្តម **វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ។

❋នាព្រឹកថ្ងៃចន្ទ ទី៣០ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យបង្សុកូលឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធជនរងគ្រោះនៃព្រឹត្តិការណ៍វាយប្រហារដោយគ្រាប់បែកដៃ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧

នៅបរិវេណស្តូបវីរបាតុករ ស្ថិតក្នុងភូមិ១ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

❈សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាង៖

-ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីទក្ខិណានុប្បទានឧទ្ទិសព្រះរាជមហាកុសលថ្វាយ «សម្តេចព្រះមហាក្សត្រិយានី **ស៊ីសុវត្ថិ មុនីវង្ស កុសមៈ នារីរ័ត្ន សេរីវឌ្ឍនា**» ស្ថិតក្នុងព្រះធម្មសាលាព្រះឧបោសថព្រះកែវមរកត ព្រះបរមរាជវាំង នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦។

-ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីសាង-ផ្សឹកវាលុកចេតិយ (ពូនភ្នំខ្សាច់) ស្ថិតក្នុងបរិវេណព្រះឧបោសថរតនារាមព្រះវិហារព្រះកែវមរកត ព្រះបរមរាជវាំង នាថ្ងៃ១១ ខែមេសា ឆ្នាំ២០២៦។

-ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីសាង-ផ្សឹកវាលុកចេតិយ (ប្រោះព្រំព្រះសុគន្ធវារី) ស្ថិតក្នុងបរិវេណព្រះឧបោសថរតនារាមព្រះវិហារព្រះកែវ-មរកត ព្រះបរមរាជវាំង នាថ្ងៃ១២ ខែមេសា ឆ្នាំ២០២៦។

-ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីទទួលទេវតាឆ្នាំថ្មី ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ មហាសករាជ១៩៤៨ ចុល្លសករាជ១៣៨៨ គ្រិស្តសករាជ២០២៦ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៦។

-ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីថ្វាយព្រះសុគន្ធវារី ថ្វាយផ្កា ថ្វាយទៀន ព្រះទេវរូបចម្រើន នូវសិរីសួស្តីជ័យមង្គល ស្ថិតក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង នាថ្ងៃ១៦ ខែមេសា ឆ្នាំ២០២៦៕

## ការទទួលពាក្យបណ្តឹង

❈ក្នុងខែមេសា ឆ្នាំ២០២៥ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្តឹងចូលចំនួន៥បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៣បណ្តឹង កំពុងពិនិត្យសិក្សាចំនួន៣បណ្តឹង រំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន៥បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន៤បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា អំពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរខេត្តពាក់ព័ន្ធ៤បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹងចំនួន១២បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន២បណ្តឹង៕

# ឯកឧត្តម ឡាយ សំកុល អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំខែកុម្ភៈនិងខែមីនា និងលើកទិសដៅការងារខែមេសា ឆ្នាំ២០២៦



*ឯកឧត្តម អោក បូរ៉ា    ឯកឧត្តម ខេង សិទ្ធិគុណ    ឯកឧត្តម ឡាយ សំកុល    ឯកឧត្តម ឡោក ឆាយ    ឯកឧត្តម ឌី បញ្ញា*

នារសៀលថ្ងៃព្រហស្បតិ៍ ១៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈនិងខែមីនា និងលើកទិសដៅការងារខែមេសា ឆ្នាំ២០២៦ នៅសាលកក្តីវិក្រម១ នៃវិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចាប់ពីប្រធាននាយកដ្ឋានឡើង។



*ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំបូកសរុប*

មានប្រសាសន៍ក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានលើកឡើងនូវចំណុចសំខាន់ៗដូចខាងក្រោម៖

១-ការបន្តផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិកសមាជិកាព្រឹទ្ធសភា លើមុខងារនីតិកម្ម រួមមានការរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងការបើកសម័យប្រជុំព្រឹទ្ធសភាលើកទី៥ នាពេលខាងមុខ និងការរៀបចំរបាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា។

២-ការបន្តសម្របសម្រួលអញ្ជើញតំណាងរាជរដ្ឋាភិបាលធ្វើបទបង្ហាញលើប្រធានបទពាក់ព័ន្ធនឹងកិច្ចការសំខាន់ៗដែលជាផលប្រយោជន៍របស់ប្រទេសជាតិ។

៣-ការរៀបចំការចុះបំពេញមុខងារតំណាងរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា រួមមាន ការអញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរដែនដី និងក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជាអង្គបោះឆ្នោតព្រឹទ្ធសភា នៅតាមបណ្តារាជធានី និងខេត្ត។

៤-ការត្រៀមរៀបចំដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាទៅក្រៅប្រទេសនិងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង (APF) និងសន្និសីទប្រធានសភានៃអន្តរសភា (ISC) នៅព្រះរាជាណាចក្រកម្ពុជា។

៥-ការកែសម្រួលនីតិវិធីនៃការវាយតម្លៃការដំឡើងថ្នាក់ជូនមន្ត្រីរាជការ ដោយផ្តោតលើគុណភាពការងារ ការឆ្លើយតប និងការចូលរួមអភិវឌ្ឍស្ថាប័ន។ ចំណុចទាំងអស់ គឺជាចលករជំរុញឱ្យមន្ត្រីរាជការបន្តអភិវឌ្ឍសមត្ថភាព មានការទទួលខុសត្រូវខ្ពស់និងកាន់តែសកម្មក្នុងការចូលរួមអភិវឌ្ឍស្ថាប័នកាន់តែរីកចម្រើនបន្ថែមទៀត។ **ឯកឧត្តមអគ្គលេខាធិការ** ក៏បានណែនាំដល់ប្រធានអង្គភាពនិងថ្នាក់ដឹកនាំដែលមានភារកិច្ចក្នុងការវាយតម្លៃនេះ ត្រូវធ្វើការវាយតម្លៃដោយឈរលើគោលការណ៍សុក្រឹតភាព យុត្តិធម៌ និងមិនលម្អៀង។

ស្របពេលជាមួយគ្នានេះ ស្ថិតក្នុងបរិការណ៍នៃវិបត្តិថាមពលប្រេងឥន្ធនៈកំពុងកើតមានឡើងនាពេលបច្ចុប្បន្ន **ឯកឧត្តមអគ្គលេខាធិការ**បានអំពាវនាវឱ្យថ្នាក់ដឹកនាំ មន្ត្រីនិងបុគ្គលិកទាំងអស់ ចូលរួមអនុវត្តវិធានការសន្សំសំចៃក្នុងការប្រើប្រាស់ថាមពលអគ្គិសនី ប្រេងឥន្ធនៈ និងការប្រើប្រាស់ធនធានសម្ភារៈផ្សេងៗ ជាពិសេសលើកទឹកចិត្តការចូលរួមកិច្ចប្រជុំនានាទាំងក្នុងនិងក្រៅប្រទេសតាមរយៈអនឡាញឱ្យបានច្រើនដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការចំណាយថវិកាចូលរួម ដែលជាវិធានការទប់ទល់នឹងផលប៉ះពាល់នៃវិបត្តិសកលសម្រាប់រយៈពេលយូរ។

នៅទីបញ្ចប់ ឯកឧត្តមបានជូនពរឱ្យថ្នាក់ដឹកនាំ មន្ត្រីនិងបុគ្គលិកទាំងអស់ សូមមានសុខភាពល្អ ធ្វើដំណើរប្រកបដោយសុខសុវត្ថិភាព ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នាពេលខាងមុខនេះ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន






*ទិដ្ឋភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈនិងខែមីនា និងកំណត់ទិសដៅការងារខែមេសា ឆ្នាំ២០២៦*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❋នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបជាមួយលោក Li Guodong លេខាធិការទី១និងលោក Zhang Yuntao លេខាធិការទី២ នៃការិយាល័យសេដ្ឋកិច្ចនិងពាណិជ្ជកម្ម នៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានសាមគ្គីភាព នៃព្រឹទ្ធសភា។





❋នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបជាមួយលោកបណ្ឌិត David Zhan នាយកប្រតិបត្តិ នៃក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា (Air Cambodia)និងសហការី នៅបន្ទប់ទទួលភ្ញៀវរបស់ឯកឧត្តមអគ្គលេខាធិការ វិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

❋នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **យស សុខេមរៈ** ប្រធានពិធីការសម្តេចអគ្គមហាសេនាបតីតេជោ ប្រធានព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកំពង់ចាម និងរដ្ឋបាលខេត្តត្បូងឃ្មុំ ដើម្បីរៀបចំសម្របសម្រួលការអញ្ជើញចុះបំពេញមុខងារតំណាងរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា នៅសាលាខេត្តកំពង់ចាម។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការពិនិត្យនិងវាយតម្លៃដំឡើងថ្នាក់ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យលើបែបបទនិងទម្រង់ក្នុងការវាយតម្លៃដំឡើងថ្នាក់មន្ត្រីរាជការតាមវេនជ្រើសរើសឆ្នាំ២០២៦និងវេនអតីតភាពឆ្នាំ២០២៦ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

---

❈នារសៀលថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងលោកជំទាវ និងឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា រួមនឹងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញជួបសំណេះ-សំណាលនិងប្រគល់អំណោយឧបត្ថម្ភជូនដល់ក្រុមសម្តែងសិល្បៈមកពីសមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារក្រីក្រ ដឹកនាំដោយលោក **ស៊ូ សាវ៉ាង** (ហៅលោកតាហ្មុយស្សូ) នៅសាលភក្តីវិក្រម១ នៃវិមានព្រឹទ្ធសភា។



---



❈នារសៀលថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងលោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញលេងល្បែងប្រជាប្រិយខ្មែរនិងរាំកម្សាន្ត ដើម្បីបង្កើតបរិយាកាសសប្បាយរីករាយនិងភាពស្និទ្ធស្នាល នៅសួនច្បារខាងមុខសាលភក្តីវិក្រម នៃវិមានព្រឹទ្ធសភា។

---

❈នារសៀលថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា អមដោយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន បានអញ្ជើញប្រគល់សម្ភារៈប្រើប្រាស់ គ្រឿងឧបភោគ បរិភោគ សម្លៀកបំពាក់ ថ្នាំពេទ្យ និងថវិកាមួយចំនួន ជូនសាលាខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នៅវិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងលោកជំទាវ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភានិងជានាយកខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភានិងលោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកជំទាវ **ថៃ អ៊ីខាហ៊ាង** ម្តាយក្មេករបស់ឯកឧត្តម **ប្រាក់ ដាវីដ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

❈នារសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍សមិទ្ធផលការងារក្នុងរយៈពេល២ខែនិងទិសដៅការងារខែមេសា របស់ខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា នៅសាលប្រជុំខុទ្ទកាល័យ វិមានសាមគ្គីភាព។





❈នារសៀលថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា អមដំណើរដោយឯកឧត្តមនាយករងខុទ្ទកាល័យនិងសហការី បានអញ្ជើញប្រគល់សារលិខិតរំលែកមរណទុក្ខ រួមជាមួយថវិការបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** និងគោរពវិញ្ញាណក្ខន្ធសព សីលាភិរ័ក្ខសិរីវិសុទ្ធា អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ផូ ត្អួង** ម្តាយបង្កើតរបស់ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនគរបាលជាតិ។

❈នាព្រឹកថ្ងៃអង្គារ ទី៣១ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គនាយកដ្ឋានសេវាច្បាប់និងសម្ហូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ ប្រចាំខែមីនា និងកំណត់ទិសដៅការងារខែមេសា ឆ្នាំ២០២៦ នៅសាលភក្តីវិក្រម៥ នៃវិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នាព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តម **ខួន សុខខេង** អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ បានអនុញ្ញាតឱ្យកញ្ញា Louise Vaudey ជានិស្សិតឆ្នាំទី៣ ផ្នែកវិទ្យាសាស្ត្រនយោបាយ នៃវិទ្យាស្ថានសិក្សានយោបាយ Aix-en-Provence (Sciences Po Aix-en-Provence)និងជាកម្មសិក្សាការីនៅនាយកដ្ឋានកិច្ចការហ្វ្រង់កូហ្វូន នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលជួបសម្តែងការគួរសមនិងជម្រាបលា។

❈នារសៀលថ្ងៃសុក្រ ទី១០ ខែមេសា ឆ្នាំ២០២៦ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ខួន សុខខេង** អគ្គនាយក បានអញ្ជើញចូលជួបសម្តែងការគួរសម និងគោរពជូនពរឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ។





❈នារសៀលថ្ងៃទី៩ និងថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ជាម សុផលមករា** អគ្គនាយក បានអញ្ជើញចូលជួបសម្តែងការគួរសម និងគោរពជូនពរឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ។

❈នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **គួក ហ៊ីដេរ៉ូ** នាយករងខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភានិងសហការី បានអញ្ជើញប្រគល់ជូននូវសារលិខិតរំលែកមរណទុក្ខ រួមជាមួយថវិការបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ព្រមទាំងគោរពវិញ្ញាណក្ខន្ធសព អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **អ៊ុក សាផន** បងស្រីបង្កើតរបស់លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា៕



សូមស្កេន QR Code

ដើម្បីចូលទៅកាន់បណ្តាញសង្គមព្រឹទ្ធសភា

**Senate of Cambodia**


វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរសព្ទ៖ (855) 23 211 411, 211 422, 211 443

ទូរសារ៖ (855) 23 211 446

E-mail: secretariat@senate.gov.kh